<u>ទំព័រទី១</u>៖ **ទស្សនាវដ្តី "និប៉ុនិកា" លេខ២៩**

# ចំណងដែលចងបេះដូងជប៉ុន

<u>ទំព័រទី២</u>៖ **មាតិកា**

ទស្សនាវដ្តីលេខនេះ និយាយអំពី "**ចំណងដែលចងបេះដូងជប៉ុន**"

- ចំណងក្នុងប្រទេសជប៉ុន៖ និមិត្តសញ្ញានៃក្តីសង្ឃឹមជាច្រើន
- ចំណងកាដូពីបេះដូង៖ កាដូតាមរបៀបអុរិហ្គាតា(Origata) និងការតុបតែងបែបមិហ្ស៊ឺហ៊ិគិ(Mizuhiki)
- ម៉ូដនៃចំណងដ៏ពេញនិយម៖ អុប៊ិ-មឹស៊ឹប៊ិ(Obi-musubi) និងគឹមិហ៊ិម៉ុ(Kumihimo)
- ភាពស្រស់ស្អាតនៃចំណង ដែលមានបច្ចេកទេសពិសេសៗ៖ ចំណងសម្រាប់ការតុបតែង និងចំណងរបង ឬស្សី
- ចំណងមនុស្ស និងមនុស្ស និងការរស់នៅ ៖ ស្ពាន
- ទីតាំងនានានៃ អេន-មឹស៊ឹប៊ិ(En-musubi)
- រសជាតិនៃប្រទេសជប៉ុន៖ ពេលវេលាទទួលទាន! ឆាគិន-ហ្ស៊ឹស៊ិ(Chakin-zushi)
- ការដើរកំសាន្តនៅប្រទេសជប៉ុន៖ នីកកុ(Nikko)
- វត្ថុអនុស្សាវរីយ៍របស់ជប៉ុន៖ សម្លៀកបំពាក់ថូផ្កា

និប៉ុនិកា ត្រូវបានបោះពុម្ពជាភាសាជប៉ុន និងប្រាំមួយភាសាផ្សេងទៀត រួមមានភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ដើម្បីណែនាំទៅកាន់ពិភពលោកអំពីប្រជាជន និងវប្បធម៌ជប៉ុនសព្វថ្ងៃនេះ។

ចំណងជើងទស្សនាវដ្តី និប៉ុនិកា មានប្រភពមកពីពាក្យ " និប៉ុន" ពាក្យជប៉ុន ដែលមានន័យថា ប្រទេសជប៉ុន។

*បោះពុម្ពដោយក្រសួងការបរទេសនៃប្រទេសជប៉ុន*

*២-២-១ កាស៊ឹមិហ្គាសិគិ សង្កាត់ជិយ៉ូដា ទីក្រុងតូក្យូ ១០០-៨៩១៩ ប្រទេសជប៉ុន*

*គេហទំព័រផ្លូវការរបស់ក្រសួង [https://www.mofa.go.jp/](https://www.mofa.go.jp/)*

*គេហទំព័រដែលផ្តល់ព័ត៌មានអំពីជប៉ុន [https://web-japan.org/](https://web-japan.org/)*

*រូបភាព៖ ការតុបតែងបែបមិហ្ស៊ីហ៊ិគិ គឺជាការចងខ្សែជារូបរាងសត្វក្រៀល ដែលតំណាងជានិមិត្តរូបនៃ អាយុយឺនយូរ និងផ្កាផ្លែអ៊ុមិ(ume)រីក ដែលបង្ហាញពីការចាប់ផ្តើមរដូវផ្ការីក។*

<u>ទំព័រទី៣</u>៖ **ចំណងដែលចងភ្ជាប់ជប៉ុន**

«របៀបចង»ជាច្រើន ត្រូវបានចែករំលែកបន្តពីមួយជំនាន់ទៅមួយជំនាន់ ដែលបង្ហាញពីសោភ័ណភាពរបស់ប្រទេសជប៉ុន។ ចំណងទាំងនេះត្រូវបានក្រងដោយរួមបញ្ចូលធាតុផ្សំនៃគំនិតជាច្រើនដូចជា ការឧទ្ទិសនានា គំនិតខ្ពង់ខ្ពស់ និងការរួមបញ្ចូលនូវវប្បធម៌ចម្រុះនានាផងដែរ។ តាមរយៈទស្សនាវដ្តីលេខនេះ យើងខ្ញុំនឹងបង្ហាញពីដួងព្រលឹងវប្បធម៌ ដែលមិនអាចរកឃើញនៅទីណាផ្សេងទៀតក្នុងពិភពលោក។

<u>ទំព័រទី៤</u>៖ **ចំណងក្នុងប្រទេសជប៉ុន៖ និមិត្តសញ្ញានៃក្តីសង្ឃឹមជាច្រើន**

**ចំណងតាមរយៈការឧទ្ទិស**

ថ្មហ្គុតុប៊ិគិ-អ៊ិវ៉ា(Gotobiki-iwa) ដ៏មហិមា រុំព័ទ្ធដោយ ស៊ិម៉ិណាវ៉ា(shimenawa) ដែលជាខ្សែចំបើងតាមបែបស៊ិនតូ (Shinto) បង្ហាញពីទីតាំងនៃទីសក្ការៈនៅលើចំណោតច្រាំងថ្ម ហៅថា អាម៉ាណុអ៊ិវ៉ាតាតិ(Amanoiwatate) ដែលត្រូវបានតំណាលតថា អាទិទេពបានមកចាប់បដិសន្ធិដំបូងលើភពផែនដី។

វិហារកាមិគឺរ៉ា(Kamikura Shrine) (វិហារគឺម៉ាណុ ហាយ៉ាតាម៉ា តៃសា(Kumano Hayatama Taisha Shrine)) ខេត្តវ៉ាកាយ៉ាម៉ា(Wakayama Prefecture)

<u>ទំព័រទី៥</u>៖

១. ស៊ិម៉ិណាវ៉ា(shimenawa) ត្រូវបានបង្កើតឡើងដោយចំណងចំបើងជាច្រើន ដែលបានមកពីការដាំដុះស្រូវ។ អ៊ិហ្ស៊ុម៉ុ អូយ៉ាស៊ិរ៉ុ(Izumo Ooyashiro) (វិហារធំអ៊ិហ្ស៊ុម៉ុ(Izumo Grand Shrine)) ខេត្តស៊ិម៉ាណិ(Shimane Prefecture)

២. ដុំថ្មភ្នំ២បានរួមគ្នាដោយស៊ិម៉ិណាវ៉ា តំណាងឱ្យគូស្វាមីភរិយាដែលតែងតែនៅក្បែរគ្នា។ ថ្មម៉ិអុតុ អ៊ិវ៉ា(Meoto Iwa) នេះ មានន័យចំថា ថ្មអាពាហ៍ពិពាហ៍ដែលជានិមិត្តរូបនៃអាពាហ៍ពិពាហ៍ដ៏រីករាយ និង គ្រួសារ។

វិហារហ្វឹតាមិ អុគិតាម៉ា(Futami Okitama Shrine) ខេត្តមិអិ(Mie Prefecture)

ទំព័រទី៦៖

**ចំណងរួមគ្នា៖** អាពាហ៍ពិពាហ៍ចងភ្ជាប់ទំនាក់ទំនងរវាងគូស្វាមី ភរិយា និងសមាជិកគ្រួសាររបស់ពួកគេ។ ចំណង ពណ៌ស នៅត្រឹមផ្នែកទ្រូងរបស់កូនក្រមុំ ត្រូវបានចងបែបអាវ៉ាជិ-មឹស៊ឺប៊ិ(Awaji-musubi) យ៉ាងតឹងណែន ដែលពុំអាចស្រាយវិញបានដោយងាយនោះទេ។

រូបថតដោយ៖ PIXTA, Getty Images

ទំព័រទី៧៖

**ចំណងទេសភាព៖** ផ្ទាំងឫស្សី គឺជាខ្សែបន្ទាត់ ហើយរុំជាមួយនឹងខ្សែពណ៌ខ្មៅដោយយកចិត្តទុកដាក់ជាទីបំផុត ដើម្បីបង្ហាញពីតុល្យភាព និងសុខដុមរមនា ជាមួយនឹងទេសភាពជុំវិញ។

តាកិណុ-មិឈិ(Take-no-Michi) (ផ្លូវឫស្សី) ខេត្តក្យូតុ(Kyoto Prefecture)

**ចំណងគ្រឿងតាំងលម្អ៖** គឺមិហ៊ិម៉ុ(Kumihimo) មានន័យថា«ខ្សែក្រង» ដែលត្រូវបានវិវត្តជាគ្រឿងតាំងលម្អចាប់តាំងពីសតវត្សរ៍ទី៨ ហើយក្រោយមកត្រូវបានប្រើជាខ្សែក្រងដ៏មាំ ទ្រលើគ្រឿងធ្វើសឹកសាម៉ូរ៉ៃធ្ងន់ៗ ដែលមានទម្ងន់រហូតរាប់សិបគីឡូក្រាមឯណោះ។

**ចំណងកាដូពីបេះដូង៖** ការប្រើប្រាស់ខ្សែដែលត្រូវបានហៅថា មិហ្ស៊ឺហ៊ិគិ (Mizuhiki) កើតពីការបត់ក្រដាសវ៉ាស៊ិ (Washi) (ក្រដាសប្រពៃណីជប៉ុនធ្វើឡើងដោយដៃ) ចង ឬ ក្រងជារាងផ្កាផ្លែអ៊ុម៉ិរីក ដើម្បីប្រើជាចំណងដៃសម្រាប់គូស្វាមីភរិយា។

ត្ស៊ឺដា មិហ្ស៊ឺហ៊ិគិ អុរិកាតា(Tsuda Mizuhiki Orikata) ខេត្តអ៊ិស៊ិកាវ៉ា(Ishikawa Prefecture)

ទំព័រទី៨៖ **ចំណងកាដូពីបេះដូង**

វត្ថុអនុស្សាវរីយ៍ត្រូវបានផ្តល់ជូនទៅនរណាម្នាក់ដែលសំខាន់សម្រាប់យើងដើម្បីបង្ហាញពីអំណរសាទរ ឬ បង្ហាញពីអំណរគុណទៅកាន់នរណាម្នាក់ដែលបានជួយយកអាសាយើង។ វប្បធម៌នៃការផ្លាស់ប្តូរវត្ថុអនុស្សាវរីយ៍គឺពិតជារីករាយខ្លាំងណាស់ និងទម្លាប់ដ៏ប្រសើររបស់ប្រជាជនជប៉ុន។ របៀបចងបែបអុរិហ្គាតាដែលមាននៅសព្វថ្ងៃនេះ បង្ហាញពីមនោសញ្ចេតនាដ៏ជ្រាលជ្រៅ និងទំនៀមទម្លាប់នានា ហើយរបៀបចងបែបមិហ្ស៊ឺហ៊ិគិវិញ គឺត្រូវបានប្រើប្រាស់ដើម្បីតុបតែងលម្អកន្លែងនៃការប្រារព្ធពិធីនានា។

*រូបថតនេះ បង្ហាញពីការងាររៀបចំដ៏ផ្ចិតផ្ចង់បែបអុរិហ្គាតា សម្រាប់ការរៀបចំតុបតែង(កាហ្សារិ(kazari)) ឆូស៊ិ (choshi-ពែងចាក់ស្រាសាកេជប៉ុន) និង ហ៊ិសាហ្គិ(hisage-ដបស្រាសាកេជប៉ុនតាមបែបប្រពៃណី)។ ពែងស្រាសាកេទាំងនេះ ត្រូវបានប្រើជាគូ ដើម្បីរំលឹកដល់ទិដ្ឋភាពសត្វមេអំបៅហោះត្រសងជាគូនៅក្នុងលំហដោយក្តីរីករាយ។*

## **ការខ្ចប់តាមរបៀបអុរិហ្គាតា** (Origata)

*អុរិហ្គាតា គឺនៅតែត្រូវបានប្រើប្រាស់រហូតដល់សព្វថ្ងៃនេះក្នុងឱកាសដូចជា ការរៀបចំបដិសណ្ឋារកិច្ចសម្រាប់ភ្ញៀវ ឬ សម្រាប់កម្មវិធីអបអរសាទរណាមួយ។*

អុរិហ្គាតា មានប្រវត្តិប្រហែល៦០០ឆ្នាំមកហើយ គឺជាបែបបទសុជីវធម៌តាមក្បួនច្បាប់នៃទំនៀមទម្លាប់យ៉ាងល្អិតល្អន់ អំពីរបៀប វេចខ្ចប់ និងចងកាដូ។ ទំនៀមទម្លាប់នេះ ត្រូវបានផ្ទេរបន្តក្នុងគ្រួសារសាម៉ូរ៉ៃ (អ្នកប្រយុទ្ធ) យ៉ាងខ្ជាប់ខ្ជួន និងក្រោយមកក៏ត្រូវបានផ្ទេរចូលក្នុងសង្គមគ្រួសារជនសាមញ្ញទូទៅផងដែរ។

កាដូ ត្រូវបានវេចខ្ចប់ក្នុងទម្រង់ដែលអ្នកទទួលងាយស្រួលស្រាយដោយដៃ។ អ្នករៀបចំ បានយកចិត្តទុកដាក់សម្រាប់អ្នកទទួលណាស់ ដោយបានទុកផ្នែកណាមួយដែលមិនបានរុំ ឬ ចង ដល់អ្នកទទួលបានមើលឃើញពីសោភ័ណភាពផ្នែកខ្លះនៃកាដូនោះ។

គេមិនប្រើកន្ត្រៃក្នុងការវេចខ្ចប់បែបអុរិហ្គាតាទេ ទោះបីជាការវេចខ្ចប់មានលក្ខណៈស្មុគស្មាញយ៉ាងណាក៏ដោយ។ ផ្ទុយទៅវិញ ការវេចខ្ចប់ ចាប់ផ្តើមដោយការបត់ក្រដាសវ៉ាស៊ិ (washi) (ក្រដាសបែបប្រពៃណីជប៉ុនធ្វើដោយដៃ) ជាប៉ុន្មានស្រទាប់ត្រួតគ្នា។ ទំហំ និងគុណភាពនៃក្រដាសវ៉ាស៊ិ បង្ហាញពីការគោរព និងត្រូវបានជ្រើសរើសយ៉ាងផ្ចិតផ្ចង់ដើម្បីតម្រូវនឹងគុណភាពនៃកាដូ ក៏ដូចជាឋានៈអ្នកទទួលកាដូនេះផងដែរ។ ក្រដាសវ៉ាស៊ិពណ៌សម៉ត់ និងឥតខ្ចោះ ត្រូវបានប្រើប្រាស់ជាពិសេស ក៏ប៉ុន្តែពេលខ្លះ ក៏ត្រូវបានបត់ជាមួយក្រដាសវ៉ាស៊ិពណ៌ស្រាលផ្សេងៗផងដែរ ដើម្បីបង្ហាញពីភាពសាមញ្ញឥតខ្ចោះ។

សម្រាប់អ្នកមានឋានៈខ្ពស់ គេប្រើខ្សែអាសាហ៊ិម៉ុ (asahimo-ខ្សែធ្វើពីក្រចៅ) និងខ្សែគិនឹហ៊ិម៉ុ (kinuhimo-ខ្សែអំបោះសូត្រ) ជាដើម ដើម្បីវេចខ្ចប់ រីឯសម្រាប់ត្រកូលសាម៉ូរ៉ៃ គេប្រើ កុយ៉ុរិ (koyori) ជាខ្សែធ្វើឡើងពីការរមូលសសៃឆ្មារៗនៃក្រដាសវ៉ាស៊ិ។

ទំព័រទី៩៖

ជាច្រើនឆ្នាំក្រោយមក គេនិយមប្រើខ្សែមិហ្ស៊ីហ៊ិគិដែលលាយជាប់ជាមួយការ ពណ៌មាស ពណ៌ប្រាក់ ពណ៌ស និង ពណ៌ក្រហម។

អុរិហ្គាតា គឺជាផ្នែកមួយនៃវប្បធម៌ប្រពៃណីជប៉ុនមានជាយូរលង់ណាស់មកហើយ ព្រមទាំងបានផ្ទេរទៅកាន់មនុស្សជំនាន់ក្រោយផងដែរ។ ប្រភេទនៃអុរិហ្គាតា គឺអាស្រ័យនឹងកាដូដែលត្រូវវេចខ្ចប់នោះ ផ្ទុយទៅវិញ ការឆ្លុះបញ្ចាំងពីអត្ថន័យនៃអុរិហ្គាតា គឺមិនអាស្រ័យលើរបៀបចងទាំងស្រុងនោះទេ គឺវាមានអត្ថន័យទូលំទូលាយ។ ការយកចិត្តទុកដាក់ចំពោះអ្នកដទៃ ក្រោមរូបភាពនៃទំនៀមទម្លាប់នៃការឱ្យកាដូនេះ គឺបន្តស្ថិតនៅក្នុងដួងចិត្តរបស់ប្រជាជនជប៉ុនរហូតដល់សព្វថ្ងៃ។

*អុរិហ្គាតា ត្រូវបានចាត់ទុកជាទម្រង់សិល្បៈមួយប្រភេទ បង្កើតពីក្រដាសវ៉ាស៊ិ។ រូបថតនេះ បង្ហាញពីការវេចខ្ចប់មួយក្នុងពិធីមង្គលការ។*

*រូបខាងឆ្វេង៖ ការវេចខ្ចប់រាងអុប៊ិ-ត្ស៊ុត្ស៊ុមិ(obi-tsutsumi) យ៉ាងប្រណិត នៃក្រដាសវ៉ាស៊ិដ៏មានតម្លៃ*

*រូបកណ្ដាល៖ យោងតាមការកត់ត្រាក្នុងសំណេរបុរាណជប៉ុន បានបង្ហាញឲ្យឃើញជាថ្មីម្ដងទៀតនូវរបៀបខ្ចប់បែប "ណុស៊ិអាវ៉ាប៊ិ-មឹស៊ិប៊ិ (Noshiawabi-mushibi)" ដែលចម្លងពីរបៀបវេចខ្ចប់ខ្យងសមុទ្រអាវ៉ាប៊ិ(awabi) ក្រៀមដែលត្រូវបានគេតៀបឲ្យមានរាងទ្រវែងដែលយើងកម្របានឃើញណាស់សព្វថ្ងៃនេះ។*

*រូបខាងស្ដាំ៖ ត្រីកាត្ស៊ឹអុក្រៀម (Katsuobushi) ដែលត្រូវបានវេចខ្ចប់សម្រាប់ជាសំណែនដល់ព្រះជាម្ចាស់។*

***លោក យ៉ាម៉ាណិ កាហ្ស៊ឹគិ (Yamane Kazuki) ដែលជានាយកសាលាយ៉ាម៉ាណិ អុរិហ្គាតា***

*លោក យ៉ាម៉ាណិ កាហ្ស៊ឹគិ បានលះបង់ពេលវេលាផ្ទាល់ខ្លួន ដើម្បីចែករំលែកវិធីសាស្ត្រ អុរិហ្គាតាដ៏មានភាពទាក់ទាញ និងគោលការណ៍ទូទៅ ដូច្នេះវប្បធម៌វ៉ាស៊ិ នឹងត្រូវបានបញ្ចូលទៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជនសម័យទំនើបនេះ។ គាត់មានប្រសាសន៍ថា «អុរិហ្គាតា គឺផ្ដោតលើការខិតខំព្យាយាម និង រក្សានូវជំនឿដ៏ល្អ ដើម្បីទំនាក់ទំនងដ៏ប្រសើរជាមួយអ្នកដទៃ។» គាត់មានប្រសាសន៍បន្តថា «ដោយផ្ដោតការយកទុកដាក់លើអ្នកដទៃបែបនេះហើយ ទើបធ្វើឱ្យទំនៀមទម្លាប់នៃអុរិហ្គាតាមិនបាត់បង់។»*

*រូបថតនៃការងារការវេចខ្ចប់ទាំងអស់ក្នុងទំព័រលេខ៨ និង៩ ធ្វើឡើងដោយលោកយ៉ាម៉ាណិ កាហ្ស៊ឹគិ*

*រូបខាងឆ្វេងផ្នែកខាងក្រោម៖ របៀបខ្ចប់បែប គឺសាបាណា-ត្សឹត្សឹមិ (Kusabana-tsutsumi) គឺតំណាងឲ្យភាពទាក់ទាញបែបជនបទ នៃផ្កាតាមរដូវដែលទើបតែកាត់ពីដើមថ្មីៗ។*

*រូបខាងស្តាំផ្នែកខាងក្រោម៖ វត្ថុដែលចាំបាច់ក្នុងជីវភាពប្រចាំថ្ងៃរបស់គ្រួសារសាម៉ូរ៉ៃ ដូចជា ជក់សរសេរ ដែលជាទូទៅត្រូវបានវេចខ្ចប់ ហើយប្រគល់ជូន តាមរបៀបវេចខ្ចប់ជាពិសេសបែបអុរិហ្គាតា ។*

<u>ទំព័រទី១០</u>៖ **ការតុបតែងបែបមិហ្សឹហ៊ិគិ** (Mizuhiki)

មិហ្ស៊ឹហ៊ិគិ គឺត្រូវបានរៀបចំឡើងដោយការបត់ក្រដាសវ៉ាស៊ិស្តើងៗ (ក្រដាសប្រពៃណីជប៉ុនធ្វើដោយដៃ) ដើម្បីបង្កើតជាខ្សែចំណង ហើយបន្ទាប់មក លាបជាមួយណុរិ(nori-កាវ)។ ការធ្វើបែបនេះ មិនត្រឹមតែងាយស្រួលពត់ ឬក្រងប៉ុណ្ណោះទេ ថែមទាំងបង្កើតភាពស្វិត ការពារភាពងាយដាច់ ហើយអាចបង្កើតបានជាទម្រង់ផ្សេងៗជាច្រើន។

មានទ្រឹស្តីមួយចំនួនរៀបរាប់អំពីប្រភពដែលមិហ្ស៊ឹហ៊ិគិ ត្រូវបានបង្កើតឡើងក្នុងប្រទេសជប៉ុន ក្នុងនោះមានមួយដែលបានរៀបរាប់ថា វាត្រូវបានបង្កើតឡើងនៅដើមសតវត្សរ៍ទី៧ នៅពេលខ្សែអាសាហ៊ិម៉ុ (asahimo-ខ្សែធ្វើពីក្រចៅ) ត្រូវបានជ្រលក់ពណ៌ក្រហម ស ដើម្បីយកចងរបស់របរខ្ចប់ទៅកាន់ព្រះបរមរាជវាំងនៃប្រទេសជប៉ុន។ នៅពេលដែលរបៀបចងបែបមិហ្ស៊ឹហ៊ិគិ ត្រូវបានគេប្រើជំនួសខ្សែអំបោះ វាបានក្លាយជាចំណងតុបតែងយ៉ាងស្រស់ស្អាត និងមានភាពលេចធ្លោជាបន្តបន្ទាប់។

ក្នុងប្រទេសជប៉ុន នៅពេលដែលគូស្វាមីភរិយារៀបអាពាហ៍ពិពាហ៍ មានពិធីប្រពៃណីមួយហៅថា យ៉ឹអ៊ិណូ(Yuino-បណ្ណាការ) សម្រាប់គ្រួសារទាំងសងខាងជួបគ្នា និងបង្កើតចំណងគូថ្មី។ តាមទំនៀមទម្លាប់នៅទីនេះ គឺការប្តូរចំណងដៃដែលបង្កប់អត្ថន័យពិសេស និងរៀបចំបានយ៉ាងស្រស់ស្អាតជាមួយការតុបតែងបែបមិហ្ស៊ឹហ៊ិគិ។

រូបសត្វក្រៀល និងសត្វអណ្តើក តំណាងឲ្យអាយុវែង ស្លឹកស្រល់ និងឫស្សី មានពណ៌បៃតងចាស់ទោះជាក្នុងអំឡុងរដូវរងាក៏ដោយ ហើយរូបផ្កាផ្លែអ៊ុម៉ិរីកមុននិទាឃរដូវ ក៏ជានិមិត្តសញ្ញាដ៏រីករាយនៅក្នុងប្រទេសជប៉ុនផងដែរ។ ការតុបតែងបែបមិហ្ស៊ឹហ៊ិគិទាំងនេះ ក្នុងឱកាសពេលប្រារព្ធពិធីនានា គឺពិតជាចំណងដៃដែលចាំបាច់ខ្លាំងណាស់។

***ចំណងបែបមិហ្ស៊ឹហ៊ិគិទូទៅ***

*រូបខាងឆ្វេង៖ ចំណងបែបមិហ្ស៊ឹហ៊ិគិទូទៅសម្រាប់ការអបអរសាទរ។ អាវ៉ាជិ-មឹស៊ឹប៊ិ( Awaji-musubi-ចំណងអបអរសាទរ) គឺពិបាកស្រាយនៅពេលដែលត្រូវបានចងហើយ។*

*រូបកណ្តាល៖ មឹស៊ឹប៊ិ-គិរិ (Musubi-kiri) ត្រូវបានប្រើប្រាស់នៅពេលដែលយើងចង់បង្ហាញពីការសាទរជាងធម្មតា។*

*រូបខាងស្តាំ៖ យ៉ុរិកាអិស៊ិ (Yorikaeshi) ជាតំណាងឱ្យ ការជូនពរសម្រាប់ជោគវាសនាល្អ ដូចជាដំណើរវិលត្រលប់នៃរលកសមុទ្រ។ ចំណងបែបនេះត្រូវបានប្រើប្រាស់សម្រាប់ពិធីផ្សេងៗ ក្រៅពីអាពាហ៍ពិពាហ៍។*

*ការតុបតែងបែបមិហ្ស៊ឹហ៊ិគិ គឺជាស្នាដៃមួយក្នុងចំណោមសិប្បកម្មប្រពៃណីតំណាងឲ្យខេត្តអ៊ីស៊ិខាវ៉ា(Ishikawa) ។ រូបថតនេះបង្ហាញការវេចខ្ចប់លុយ ជាចំណងដៃសម្រាប់ពិធីមង្គលការ។*

<u>ទំព័រទី១១</u>៖

**ការតុបតែងបែបមិហ្ស៊ឹហ៊ិគិ ត្រូវបានធ្វើឡើងដើម្បីលម្អក្នុងពិធីបុណ្យ។**

**ឧទាហរណ៍ខ្លះ ក៏ត្រូវបានរៀបចំជាចំណងដៃនៃពិធីរៀបអាពាហ៍ពិពាហ៍**

**តោះក្រឡេកមើលអត្ថន័យនៃការអបអរសាទរ តាមរយៈការតុបតែងនីមួយៗ។**

**តុម៉ុស៊ិរ៉ាហ្គា (Tomoshiraga)**

តុម៉ុស៊ិរ៉ាហ្គា មានន័យថា «នៅជាមួយគ្នារហូតដល់ចាស់សក់ស្កូវ។» គេប្រើខ្សែចំណងធ្វើពីអំបោះក្រចៅដ៏ស្វិតដែលមិនអាចស្រាយបាន ហើយក៏តំណាងឱ្យស្វាមី និងភរិយា ដែលរស់នៅជាមួយគ្នាយ៉ាងមានសុភមង្គលរហូតដល់ចាស់។

**យឺអ៊ិណូគីន ត្ស៊ឹត្ស៊ឹមិ (Yuinokin tsutsumi-ការខ្ចប់អំណោយប្រាក់ថ្លៃបណ្ណាការ)**

លុយ ដាក់ក្នុងប្រអប់ដែលត្រូវបានវេចខ្ចប់បានយ៉ាងស្រស់ស្អាត។ ចំនួនលុយនោះ គឺបានសរសេរដោយជក់ ដែលមិនអាចលុបបានទេ នេះជាទំនៀមទម្លាប់ដែលបន្សល់ទុករហូតមកដល់សព្វថ្ងៃនេះ។

**កុមប៊ឹ (kombu)**

កុមប៊ឹ ឬ សារ៉ាយសមុទ្រ ត្រូវបានប្រើប្រាស់ជាញឹកញាប់ក្នុងពិធីនានា ដោយសារតែពាក្យនេះ មានសម្លេងស្រដៀងនឹង «យ៉ុរ៉ុកុប៊ឹ» (yorokoku) ដែលមានន័យថា រីករាយ។ វាក៏តំណាងឲ្យ របស់មានជីវជាតិផងដែរ។

## ស៊ឺអិហ៊ិរ៉ុ (Suehiro)

ស៊ឺអិហ៊ិរ៉ុ សំដៅទៅលើផ្លិតប្រពៃណី ប្រើប្រាស់ក្នុងឱកាសពិធីបុណ្យប្រពៃណីផ្សេងៗ។ វាតំណាងឱ្យក្រុមគ្រួសារទាំងសងខាង ហើយបន្តរីកចម្រើន និងរស់នៅដោយភាពរីករាយជារៀងរហូត។

មីហ្ស៊ឹហ៊ិគិ ប្រើប្រាស់ក្នុងស៊ឺអិហ៊ិរ៉ុ មានប្រវែងប្រហែល៩០សង់ទីម៉ែត្រ ហើយមិនត្រូវកាត់វាជាដាច់ខាត។ ដោយសារតែវាត្រូវបានគេចាត់ទុកថា ជា "អេន (en-និស្ស័យចំណង)" ។ ប្រសិនបើវាវែងជ្រុល គេនឹងសម្រួលវាដោយមូរឡើង។

## ប្រអប់ចិញ្ចៀន

អាវ៉ាជិ-មឹស៊ឹប៊ិ(awaji-musubi) គឺជាការតុបតែងបែបមិហ្ស៊ឹហ៊ិគិ ដែលល្អឥតខ្ចោះ សម្រាប់ចំណងដៃដោយអស់ពីចិត្ត។

ត្ស៊ឹដា មិហ្ស៊ឹហ៊ិគិ អុរិកាតា (Tsuda Mizuhiki Orikata) ដែលមានប្រវត្តិប្រហែល១០០ឆ្នាំចាប់តាំងពីការបង្កើតទៅតាមមូលដ្ឋានប្រពៃណីបែបអុរិហ្គាតា(origata) ក៏ប៉ុន្តែវាក៏មានការច្នៃបង្កើតរួមគ្នាជាមួយនឹងសិល្បៈការងារដ៏ស្រស់ស្អាតបែបមិហ្ស៊ឹហ៊ិគិផងដែរ។ នេះគឺការរក្សានូវប្រពៃណីចំណងរួមគ្នាបែបមនោសញ្ចេតនា ច្របាច់បញ្ចូលគ្នាជាមួយនឹងរបៀបរស់នៅសម័យទំនើប។

រូបថតនេះ គឺលោកត្ស៊ឹដា រ៉ុគឹស៊ឹកិ (Tsuda Rokusuke) ជាអ្នកបន្តវេនជំនាន់ទី៥។

លោកមានប្រសាសន៍ថា «ចំណងអាពាហ៍ពិពាហ៍ គឺមានតម្លៃខ្លាំងណាស់ក្នុងការបង្កើតចំណងរវាងក្រុមគ្រួសារកូនក្រមុំ និងកូនកំលោះ។» លោកបន្តថា «ចំណងដៃនីមួយៗមានអត្ថន័យផ្សេងៗគ្នា ហើយយើងតុបតែងបែបមិហ្ស៊ឹស៊ិគិ ដោយចេញពីចិត្ត។ ការតាំងចិត្តរបស់ពួកយើង គឺបង្កើតវាឱ្យមានភាពស្រស់ស្អាត តាមដែលអាចធ្វើទៅបានសម្រាប់ពិធី។»

## ទំព័រទី១២៖ **ម៉ូដនៃចំណងដ៏ពេញនិយម៖**

**អុប៊ិ-មឹស៊ឹប៊ិ**( Obi-musubi ) (**ចំណងខ្សែក្រវ៉ាត់**)

ជាមួយនឹងការមកដល់នាសតវត្សរ៍ទី១៨ នៅអេដុ (តូក្យូបច្ចុប្បន្ន) មានចំនួនប្រជាជនកើនដល់មួយលាននាក់ ហើយបានក្លាយជាទីក្រុងដែលមានតម្រូវការប្រើប្រាស់ដ៏ច្រើនមួយក្នុងពិភពលោក។ ខណៈពេលដែលសង្គ្រាមត្រូវបានបញ្ចប់ សង្គមបានក្លាយជាសន្តិភាព ពាណិជ្ជករ និងសិប្បករកាន់តែច្រើនចាប់ផ្តើមបង្កើតនូវវប្បធម៌ចម្រុះ ទន្ទឹមនឹងការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងវិស័យសេដ្ឋកិច្ចផងដែរ។

អុប៊ិ-មឹស៊ឹប៊ិ បានក្លាយជាម៉ូដដ៏ពេញនិយមកំឡុងពេលនេះផងដែរ។ ពីមុន អុប៊ិ(Obi) គ្មានប្រើអ្វីក្រៅពីធ្វើជាខ្សែក្រវ៉ាត់ចងជាមួយគីម៉ូណូ(Kimono)ប៉ុណ្ណោះ។ វាបានវិវត្តរូបភាពទៅជាធំជាងមុន និងវែងជាងមុន គឺជាសម្ភារៈដែលមនុស្សប្រើប្រាស់លើសពីមុខងាររបស់ខ្លួន ពោលគឺ វាមើលទៅទាន់សម័យ។

អុប៊ិ បានវិវត្តជាផ្នែកនៃសម្លៀកបំពាក់ដែលមានជាច្រើនទម្រង់ ទាំងក្រឡា ពណ៌ និងម៉ូដ ដែលធ្វើឱ្យក្លាយជាការបង្កើតថ្មី ដែលជាទំនោរថ្មី។

នាពេលនោះ ក៏មានប្រព័ន្ធបែកចែកឋានន្តរសក្តិក្នុងសង្គមផងដែរ ដោយគេគិតទៅលើមុខរបរ ដូចជា ក្រុមសាម៉ូរៃ ក្រុមកសិករ ក្រុមសិប្បករ និងក្រុមពាណិជ្ជករ ដោយសារតែបែបនេះហើយទើបមានវិធីសាស្ត្រជាក់លាក់ក្នុងការចងអុប៊ិ យោងទៅតាមមុខរបរនោះ។ ដូច្នេះតាមរយៈការចងអុប៊ិ វាអាចវែកញែកបាន ពីតួនាទីសង្គម មុខរបរ ស្ថានភាពអាពាហ៍ពិពាហ៍ និងជាច្រើនទៀត ។ តាមគោលការណ៍ទាំងអស់នោះ ប្រជាជនបង្ហាញភាពច្នៃប្រឌិត និងពីម៉ូដរបស់ពួកគេចេញមកជាមួយនឹងអុប៊ិ មឹស៊ឹប៊ិ ប្រភេទចម្រុះ។

និន្នាការម៉ូដនៃសម័យនោះអាចមើលឃើញពីរូបរាងរបស់នារីម្នាក់នៅអេដុ ដែលគូរដោយលោកហ៊ិស៊ិកាវ៉ា ម៉ូរ៉ុណុប៊ឹ (Hishikawa Moronobu) ដែលត្រូវបានគេនិយាយថាជាបុព្វបុរសរបស់គំនូរអ៊ុគិយ៉ូអិ (ukiyo-e គំនូរជប៉ុនដែលបោះពុម្ពឡើងពីពុម្ពឈើ) ដែលគំនូរនេះបង្ហាញពីពេលដែលនារីម្នាក់ឈប់ ហើយមើលទៅក្រោយ។ ជាយនៃអូប៊ិចងទម្លាក់សំយ៉ុងខាងឆ្វេង និងខាងស្តាំ ដែលត្រូវបានស្គាល់ថាជា របៀបចងគិឈិយ៉ា-មឹស៊ឹប៊ិ (kichiya-musubi) ដែលត្រូវបានបង្ហាញដោយលោកអ៊ុអិមឹរ៉ា គិឈិយ៉ា (Uemura Kichiya) ជាអុនណាហ្គាតា (Onnagata) ដ៏ពេញនិយម (តួសម្តែងប្រុសក្នុងល្ខោនបុរាណជប៉ុន កាប៊ឹគិ ដើរតួជាស្រី)។ ស្ត្រីវ័យក្មេងក្នុងសម័យអេដុ គឺឈ្លក់វង្វេងនឹងរបៀបចងអុប៊ិ-មឹស៊ឹស៊ឹប៊ិនេះ។

សិល្បករលោកហ៊ិស៊ិកាវ៉ា ម៉ូរ៉ុណុប៊ឺះ ស្នាដៃ«មិកាអិរិ ប៊ិជិន-ហ្ស៊ឺ (Mikaeri Bijin-zu) (សម្រស់មើលពីខាងក្រោយ)» នៅសតវត្សរ៍ទី១៧

ប្រភព៖ ColBase គេហទំព័រ https://colbase.nich.go.jp/)

លោកស្រីម្នាក់នេះសិក្សាយល់បានភ្លាមៗនូវសម្ភារៈរបស់អ៊ុប៊ិ និងរូបរាងកាយមនុស្ស ហើយគាត់ចងអ៊ុប៊ិមួយនេះបានជាទម្រង់ដ៏អស្ចារ្យយ៉ាងលឿន។

**របៀបចងបែប តាតិយ៉ា-ណុ-ជិ- មឹស៊ឹប៊ិ (Tateya-no-ji-musubi)**

របៀបចងបែបតាតិយ៉ា-ណុ-ជិ-មឹស៊ឹប៊ិ គឺជាការចងអ៊ុប៊ិ ដោយឱ្យចេញរៀងបញ្ឈិតកែងអ៊ុប៊ិទៅលើស្មាស្តាំនៅពេលដើរក្នុងប្រាសាទ និងបញ្ឈិតកែងអ៊ុប៊ិទៅលើស្មាឆ្វេងវិញ នៅពេលដើរនៅខាងក្រៅប្រាសាទ។

**របៀបចងបែប ហ្វ៊ឹគឺរ៉ាស៊ឹហ្ស៊ឹម៉ិ(Fukura suzume)**

របៀបចងបែបហ្វ៊ឹគឺរ៉ាស៊ឹហ្ស៊ឹម៉ិ វិវត្តមកពីតាតិយ៉ា-ណុ-ជិ-មឹស៊ឹប៊ិ។ អ៊ុប៊ិ-មឹស៊ឹប៊ិ នេះ គឺនៅតែពេញនិយមនាពេលសព្វថ្ងៃនេះ នៅពេលស្ត្រីវ័យក្មេងស្លៀកគីម៉ុណូ។

<u>ទំព័រទី១៣៖</u>

រហូតមកដល់ឥឡូវនេះ មានច្រើនជាងមួយរយរបៀបក្នុងការចងអ៊ុប៊ិ ប៉ុន្តែភាគច្រើនគឺចងតាមម៉ូដក្នុងសម័យអេដូ (1603-1868)។ វប្បធម៌នេះ បានបន្តពីមួយជំនាន់ទៅមួយជំនាន់ អស់ជាច្រើនជំនាន់។

លោកស្រី សាសាជិម៉ា ស៊ឹមិ(Sasajima sumi) ស្រាវជ្រាវលើវប្បធម៌អ៊ុប៊ិ និងបានសិក្សាលើសិល្បៈនៃការស្លៀកគីម៉ុណូ ក្នុងបរិបទការបង្ហាញសិល្បៈបែបបុរាណ។ លោកស្រីចំណាយពេលពាក់កណ្តាលសតវត្សរ៍ ដើម្បីសិក្សាលើប្រវត្តិ និងសារសំខាន់នៃអ៊ុប៊ិ-មឹស៊ឹប៊ិក្នុងវប្បធម៌ជប៉ុន ទន្ទឹមនឹងនេះ លោកស្រីក៏បានបង្រៀន និងណែនាំទាំងក្នុងប្រទេសជប៉ុន និងនៅក្រៅប្រទេស ពីរបៀបស្លៀកគីម៉ុណូ។ លោកស្រីមានប្រសាសន៍ថា «ការចងអ៊ុប៊ិ គឺប្រៀបបានទៅនឹងការហ្វឹកហាត់ចិត្ត និងពង្រឹងខ្លួនឯងផងដែរ។»

រៀងរាល់ខែមករា ពិធីពេញវ័យ ត្រូវបានប្រារព្ធឡើងទូទាំងប្រទេសជប៉ុនដើម្បីអបអរសាទរយុវជនពេញវ័យ២០ឆ្នាំ ដែលជាអាយុពេញវ័យផ្លូវការ។ ក្មេងស្រីជាច្រើនចូលចិត្តស្លៀក ហ្វឺរិសុដិ គីម៉ុណូ(furisode kimono) (គីម៉ុណូដែលមានដៃវែង) ដើម្បីចូលរួមពិធីបុណ្យ។ រូបថតនេះបង្ហាញពីការរៀបចំក្នុងសម័យបច្ចុប្បន្ន ដែលហៅថា តាតិយ៉ា-ណុ-ជិ-មឹស៊ឺប៊ិ(tateya-no-ji-musubi) និង ប៊ឺនកុ-មឹស៊ឺប៊ិ(bunko-musubi)។

**របៀបចងបែប ប៊ឺនកុ-មឹស៊ឺប៊ិ(bunko-musubi)**

របៀបចងបែប ប៊ឺនកុ-មឹស៊ឺប៊ិ អាចចងយ៉ាងតឹងណែន និងមិនងាយស្រាយនោះទេ។ ការចងដែលស្រគត់ស្រគំ និងប្រកបដោយភាពថ្លៃថ្នូរនេះ បង្ហាញពីសារៈសំខាន់របស់ស្ត្រីក្នុងគ្រួសារសាម៉ូរ៉ៃ។

**របៀបចងបែប ត្ស៊ឺណុដាសុិ-មឹស៊ឺប៊ិ (Tsunodashi-musubi)**

របៀបចងបែប ត្ស៊ឺណុដាសុិ-មឹស៊ឺប៊ិ ដែលមើលទៅមានទម្រង់ប៉ោងនៅផ្នែកខាងក្រៅ និងរម្យទម គឺជាម៉ូដចងរបស់អ្នកទីក្រុង។

**របៀបចងបែប អុតាអុិកុ-មឹស៊ឺប៊ិ (Otaiko-musubi)**

របៀបចងបែប ត្ស៊ឺណុដាសុិ-មឹស៊ឺប៊ិ ត្រូវបានរៀបចំឱ្យកាន់តែសាមញ្ញ និងប្តូររូបរាងទៅជាមានខ្សែមួយប្រើសម្រាប់រក្សាលំនឹងអុប៊ិ-មឹស៊ឺប៊ិ បានក្លាយទៅជារបៀបចងបែប អុតាអុិកុ-មឹស៊ឺប៊ិ។ រូបរាងនេះ គឺបានរីកសាយភាយទៅកាន់ប្រជាជនគ្រប់គ្នា។

**របៀបចងបែប កាតា-បាសាមិ (Kata-basami)**

របៀបចងបែប កាតា-បាសាមិ គឺជាខ្សែចំណងប្រើប្រាស់ក្នុងគ្រួសារសាម៉ូរ៉ៃ ដែលអាចចងបានយ៉ាងងាយស្រួល និងមានសុវត្ថិភាព។ នៅពេលយើងសៀតដាវក្នុងអុប៊ិនៅនឹងចង្កេះនោះ នឹងធ្វើខ្សែក្រវ៉ាត់អូប៊ិនេះកាន់តែរឹតតឹងណែនល្អ ព្រមទាំងឥរិយាបថនឹងប្រសើរជាងមុន។

ទំព័រទី១៩៖

**គឹមិហ៊ិម៉ុ** ( Kumihimo ) ( **ខ្សែក្រង** )

*ថតដោយ៖ តាគិស៊ិម៉ា យ៉ុជិ (Takishima Yoji) , រូបថតដោយ៖ ហ្គេតធី អ៊ីម៉េច, អាម៉ាណាអ៊ិម៉េច (Getty Images, amanaimages)*

គឹមិហ៊ិម៉ុ (Kumihimo) គឺជាខ្សែដែលធ្វើពីការត្បាញសូត្រ ឬ សរសៃអំបោះ។ វាបានក្លាយជាមានប្រជាប្រិយក្នុងចំណោមអ្នកអភិជននៅសតវត្សរ៍ទី៨ ដោយវិធីសាស្ត្រនៃការត្បាញគឹមិហ៊ិម៉ុ ដែលមានភាពខុសប្លែកគ្នា និងទំនើបត្រូវបានបង្កើតឡើងបន្តិចម្តងៗ ដើម្បីបង្កើតវប្បធម៌តុបតែងនៅជុំវិញខ្លួន។ ក្នុងនាមគឹមិហ៊ិម៉ុ ជាស្នាដៃសិល្បៈដ៏ឆើតឆាយ និងល្អិតល្អន់ វាត្រូវបានគេប្រើដើម្បីតុបតែងសម្លៀកបំពាក់ និងវត្ថុសក្ការៈបូជាព្រះពុទ្ធសាសនា ព្រមទាំងជាខ្សែដាវសម្រាប់អភិជនផងដែរ។ ដោយសារប្រទេសជប៉ុនបានក្លាយជាសង្គមសាម៉ូរ៉ៃនៅសតវត្សរ៍ទី១២ គឹមិហ៊ិម៉ុ ក៏បានក្លាយជាមានប្រជាប្រិយក្នុងចំណោមសាម៉ូរ៉ៃ មិនត្រឹមតែមានភាពស្រស់ស្អាតប៉ុណ្ណោះទេ ថែមទាំងលក្ខណៈពិសេសរបស់វាដូចជា មានភាពរឹងមាំ និងការបត់បែនបានល្អ ដែលធ្វើឱ្យវាមានប្រយោជន៍សម្រាប់ការទ្រគ្រឿងសឹក និងឧបករណ៍ផ្សេងទៀតដែលមានទំងន់រាប់សិបគីឡូក្រាម។

នៅសតវត្សរ៍ទី១៧ ដល់១៨ ការធ្វើខ្សែចងដាវដោយប្រើគឹមិហ៊ិម៉ុ ហៅថាសាហ្គិអុ(sageo) បានរីកដុះដាលនៅអេដុ (តូក្យូបច្ចុប្បន្ន)។ វាត្រូវបានគេនិយាយថាសាម៉ូរ៉ៃជាច្រើនបានស្ទាត់ជំនាញលើបច្ចេកទេសនៃការត្បាញគឹមិហ៊ិម៉ុ ដោយសារតែឧបករណ៍ប្រយុទ្ធត្រូវបានគេចាត់ទុកថាសាម៉ូរ៉ៃដឹងពីរបៀបផលិតវាដោយខ្លួនឯង។

ទោះយ៉ាងណាក៏ដោយ ការប្រើប្រាស់ដាវត្រូវបានហាមឃាត់ក្នុងឆ្នាំ១៨៧៦។ សិប្បករ និងឈ្មួញ ធ្វើសាហ្គិអុ បានបាត់បង់មុខរបរពួកគេ។ ហេតុដូច្នេះហើយពួកគេក៏បានយកចិត្តទុកដាក់ចំពោះអុប៊ិជិម៉ិ(obijime) ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងសាហ្គិអុ វិញ។

*សាហ្គិអុ (Sageo) ដែលសាមូរ៉ៃ រុំព័ទ្ធដាវរបស់ពួកគេ។*

*អុប៊ិជិម៉ិ (obijime) ត្រូវបានចងចុងក្រោយគេ ចំពាក់កណ្តាលអុប៊ិ(obi)។*

ទំព័រទី១៥៖

អុប៊ិជិមិ(obijime) គឺជាខ្សែដែលសម្រាប់ចងនៅជុំវិញចំកណ្ដាលអុប៊ិ ដើម្បីជាការបញ្ចប់ការចងខ្សែចង្កេះ អុប៊ិ-មឹស៊ឹប៊ិ(obi-musubi) នៅត្រង់កន្លែងកំណត់នោះ។ អុប៊ិជិមិ កាន់តែមានប្រជាប្រិយភាពយ៉ាងធំទូលាយ ដោយសាររបៀបចងបូក្រវ៉ាត់ចង្កេះបែប អុតៃកុ-មឹស៊ឹប៊ិ(otaiko-musubi) ដែលស្ត្រីៗត្រូវការខ្សែក្រវ៉ាត់មានភាពរឹងមាំ នាំឲ្យគឹមិហ៊ិម៉ុ ក៏ទទួលបាននូវតម្រូវការជាថ្មី ហើយវាក៏រស់ឡើងវិញ។ ដូច្នេះ គឹមិហ៊ិម៉ុ បានដើរតួយ៉ាងល្អប្រសើ ជាមួយសម្លៀកបំពាក់គីម៉ុណូ ហើយបានអភិវឌ្ឍយ៉ាងឆាប់រហ័ស ក្លាយជាគ្រឿងដ៏សំខាន់នាពេលបច្ចុប្បន្ន នៅក្នុងវប្បធម៌គីម៉ុណូរបស់ជប៉ុន។

*ហាងដូម្យ៉(domyo) បានបង្កើតខ្សែគឹមិហ៊ិម៉ុ(kumihimo) នៅអ៊ុអិណុ(Ueno) ទីក្រុងតូក្យូ អស់រយៈពេលជាង៣៦០ឆ្នាំហើយ ចាប់តាំងពីបង្កើតឡើងក្នុងឆ្នាំ១៦៥២។ អុប៊ិជិមិ(obijime) ជាង៥០០ ប្រភេទតែងតែអាចរកបាននៅក្នុងហាងនេះ។*

*លោក ដូម្យ៉ គិអ៊ិឈិរ៉ុ (Domyo Kiichiro) គឺជាម្ចាស់ហាងជំនាន់ទី១០ នៃហាងដូម្យ៉ (Domyo)។*

*លោកបានចូលរួមក្នុងការផលិតខ្សែគឹមិហ៊ិម៉ុ(kumihimo)បែបថ្មី ដោយប្រើបច្ចេកទេសត្បាញបែបប្រវត្តិសាស្ត្រដែលនៅតែបន្សល់មានទូទាំងប្រទេសជាតិរូ។ លោកមានប្រសាសន៍ថា" សោភ័ណភាពជប៉ុនតែមួយគត់ត្រូវបានបញ្ចូលទៅក្នុងខ្សែគឹមិហ៊ិម៉ុដ៏តូចដែលវាស់ទៅមានទំហំត្រឹមតែពីរបីសង់ទីម៉ែត្រប៉ុណ្ណោះ" ។ ខ្ញុំសង្ឃឹមថា ខ្ញុំនឹងសាកល្បងដោយខ្លួនឯងនូវផ្នែកបច្ចេកទេសដោយការរួមបញ្ចូលគ្នានូវសម្ភារៈផ្សេងៗ ដើម្បីបង្កើតទំនាក់ទំនងថ្មីដែលសមស្របទៅនឹងរបៀបរស់នៅសម័យទំនើប។*

ទំព័រទី១៦៖

## ភាពស្រស់ស្អាតនៃចំណង ដែលមានបច្ចេកទេសពិសេសៗ

### ចំណងសម្រាប់ការតុបតែង

ចំណងខ្សែតែមួយអាចប្រែក្លាយវាទៅជាកូនសោរ ឬ ផ្កាដ៏ស្រស់ស្អាត។ ទោះយ៉ាងណាក៏ដោយការចងភ្ជាប់គ្នាយ៉ាងល្អិតល្អន់បែបនេះ ក៏នឹងត្រលប់ទៅជាខ្សែមួយវិញ នៅពេលដែលត្រូវបានស្រាយចេញ។ អស់ពេលជាច្រើនឆ្នាំមកហើយ ការតុបតែងលម្អបានធ្វើឱ្យមានការផ្លាស់ប្តូរដ៏ស្រស់ស្អាតតាមរយៈស្នាដៃដ៏ល្អប្រណិត និងថ្លៃថ្នូររបស់ប្រជាជនជប៉ុន។

សមត្ថភាពក្នុងការបង្កើតការតុបតែងដ៏ប៉ិនប្រសប់ និងគួរឱ្យភ្ញាក់ផ្អើលត្រូវបានគេចាត់ទុកថាជាជំនាញដ៏សំខាន់សម្រាប់ស្ត្រីអភិជននៅសតវត្សរ៍ទី១២។ ដូច្នេះវាត្រូវបានគេចាត់ទុកថាជាជំនាញសំខាន់បំផុតមួយដែលពួកគេបានសិក្សា។ កំឡុងពេលនេះ ហាណា-មឹស៊ឺប៊ិ (hana-musubi) ដែលមានន័យថា "ចំណងផ្កា" បានមានប្រជាប្រិយភាព។

ទោះយ៉ាងណាក៏ដោយ ប្រវត្តិសាស្ត្រនៃការតុបតែងលម្អនៃ ហាណា-មឹស៊ឺប៊ិ បានជួបការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងសម័យសង្គ្រាមនៅចុងសតវត្សរ៍ទី១៥ រហូតដល់ចុងសតវត្សទី១៦។ មេដឹកនាំសាម៉ូរ៉ៃ បានផ្តល់តម្លៃចំពោះពិធីលៀងតែ ប៉ុន្តែពួកគេខ្លាចការដាក់ថ្នាំបំពុលក្នុងតែ។ ដើម្បីបញ្ចៀសបញ្ហានេះអ្នកជំនាញតែ ដែលបម្រើមេដឹកនាំសាម៉ូរ៉ៃ បានផ្តួចផ្តើមទំនៀមទម្លាប់ចងកាបូបដាក់ម្សៅតែតាមវិធីស្មុគស្មាញផ្ទាល់ខ្លួនដែលមិនអាចយកតម្រាប់តាមបាន។ ប្រសិនបើចៃដន្យចំណងនេះអាចត្រូវបានលាចេញ នោះវាមិនអាចទៅរួចទេក្នុងការចងវាម្តងទៀតតាមរបៀបដូចគ្នា ដែលធ្វើឱ្យពួកគេដឹងច្បាស់ថាចំណងកាបូបដាក់ម្សៅតែនេះ ត្រូវបាននរណាម្នាក់ស្រាយវាហើយ។ ចំណងដែលមិនអាចស្រាយបានទាំងនេះ ត្រូវបានគេហៅថា ហ្វ៊ីអ៊ីជិ-មឹស៊ឺប៊ិ(fuuji-musubi) មានន័យថា "ចំណងបិទត្រា" ដែលជាខ្សែតែមួយដែលមានមុខងារយ៉ាងសំខាន់។

*ហ្វ៊ីអ៊ីជិ-មឹស៊ឺប៊ិ(fuuji-musubi) បានដើរតួជាកូនសោរ ខណៈពេលដែលទម្រង់ចំណាងនៃការតុបតែងចងយ៉ាងស្រស់ស្អាត។*

*ក្នុងកំឡុងសម័យអេដូ (១៦០៣-១៨៦៨) ជំនាញក្នុងការបង្កើតភាពស្រស់ស្អាតពិតប្រាកដរបស់ហាណា-មឹស៊ឺប៊ិ (hana-musubi) ត្រូវបានកែលម្អឡើងសម្រាប់ប្រើលើថង់ដែលដាក់ម្សៅតែ និងគ្រឿងអលង្ការ។*

*លោកស្រី សិគិណិ មិយឹគិ (Sekine Miyuki) គឺជាអ្នកស្រាវជ្រាវអំពី មឹស៊ឺប៊ិ(musubi)(ចំណង) និងជាសិល្បករម្នាក់ដែលធ្វើឱ្យរដូវកាល និងព្រឹត្តិការណ៍របស់ជប៉ុនមានលក្ខណៈផ្សេងៗគ្នាដោយ មឹស៊ឺប៊ិ។ សកម្មភាពច្នៃប្រឌិតរបស់លោកស្រី រួមមានការបន្តនូវ មឹស៊ឺប៊ិ ក្នុងពិធី និងព្រឹត្តិការណ៍បុរាណ ដោយផ្អែកលើឯកសារប្រវត្តិសាស្ត្រ និងសម្ភារៈផ្សេងទៀត។*

*គឹស៊ឺដាម៉ា (Kusudama) គឺខ្សែប្រាំពណ៌ដែលព្យួរលើថង់ដាក់គ្រឿងក្រអូប និងឱសថ។ គឹស៊ឺដាម៉ា នៅក្នុងរូបថតនេះ ត្រូវបានចងដោយ ខ្សែគឹមិហិម៉ុ (kumihimo)។*

*ស្នាដៃទាំងអស់នៅលើទំព័រទី១៦នេះ គឺចងដោយ លោកស្រី សិគិណិ មិយឹគិ (Sekine Miyuki)។*

ទំព័រទី១៧៖

**ចំណាងរបងឫស្សី**

របងឫស្សី ត្រូវបានគេចងដោយឫស្សី ហើយលើសពីការខណ្ឌចែកបរិវេណ របងទាំងនេះក៏ធ្វើជាទេសភាពដ៏ទាក់ទាញសម្រាប់សួនច្បារជប៉ុនជាច្រើនផងដែរ។ នៅពាក់កណ្តាលសម័យអេដុ (១៦០៣-១៨៦៨) របងឫស្សីជាច្រើនត្រូវបានគេបង្ហាញថាជាគំនូរទាន់សម័យនៅក្នុងគំនូរអ៊ុគិយ៉ុ-អិ(ukiyo-e) (គំនូរជប៉ុនដែលបោះពុម្ពឡើងពីពុម្ពឈើ) ហើយត្រូវបានគេយកទៅប្រើនៅផ្ទះរបស់ប្រជាជនសាមញ្ញ។

របងឫស្សីអាចត្រូវបានសាងសង់ដើម្បីធ្វើឱ្យសួនច្បារខាងក្នុងអាចមើលឃើញពីខាងក្រៅ ឬ ធ្វើឱ្យសួនច្បារខាងក្នុងមើលទៅមិនសូវច្បាស់។ វិធីសាស្រ្តចងដោយប្រើខ្សែពួរពណ៌ខ្មៅ (ភាសាជប៉ុន ហៅថា ខ្សែស៊ីរ៉ុ ណាវ៉ា (shuro nawa) "shuro" គឺជាឈ្មោះរុក្ខជាតិម្យ៉ាងស្រដៀងដើមត្នោត) ដែលមានភាពខុសប្លែកគ្នា ពីការចងបែបស្អាតសាមញ្ញៗ ទៅជាការតុបតែងដោយចំណាងបីវិមាត្រ(ទទឹង បណ្តោយ និងកំពស់) ដែលមានចុងខ្សែចងព្យួរវែង។ ទោះជាយ៉ាងណាក៏ដោយ ភាពផ្ទុយគ្នាយ៉ាងស្រស់ស្អាតនៃពណ៌រវាងគុម្ពឫស្សី និងខ្សែពួរបានបន្ថែមសោភ័ណភាពពិសេស ដល់ទេសភាពនៃទីក្រុងជប៉ុន ព្រមគ្នាជាមួយនឹងការចាំងត្រឡប់ដោយពណ៌ចម្រុះយ៉ាងសំបូរបែបនៃរដូវទាំងបួនរបស់ជប៉ុន។

*របងកេននីនជិ (Kenninji) ដាក់ឈ្មោះតាមវត្តមួយនៅក្យូតូដែលល្បីល្បាញដោយសារសួនច្បារដ៏ស្រស់ស្អាត និងរបងឫស្សី។ វាផ្តល់នូវភាពដាច់តែឯង ពីភាពអ៊ូអរនៅខាងក្រៅ ដែលធ្វើឲ្យបង្កើតបាននូវកន្លែងមួយយ៉ាងស្ងប់ស្ងាត់។*

*ការប្រើក្បាច់ចងល្អបំផុតក្នុងចំណោមប្រភេទក្បាច់ជាច្រើន វាគឺជាការបញ្ជាក់ពីកម្រិតនៃសិល្បៈហត្ថកម្មរបស់សិប្បករ។*

*របងឫស្សីនេះស្ថិតនៅវត្តកុអិត្ស៊ឺ (Koetsu) ក្នុងទីក្រុងក្យូតុ (Kyoto) ដែលល្បីល្បាញដោយសារសួនច្បារជប៉ុន។ ចម្រៀកឫស្សីត្រូវបានចងតាមរាងចតុកោណស្មើ ដែលបានផ្តល់នូវទិដ្ឋភាពនៃរបងម្ខាងទៀត។*

*លោក ហាដា តាមិគិ (Hada Tamiki) នៃ ហាដា ហ្សុអេន(Hada Zoen) ម្នាក់ក្នុងចំណោមអ្នករៀបចំប្លង់ដីពីរបីនាក់នាពេលបច្ចុប្បន្ននេះ ដែលបានអភិរក្សប្រពៃណីនៃបច្ចេកទេសធ្វើរបងឫស្សី។ ការងាររបស់លោក បានរួមបញ្ចូលទាំងការជួសជុល និងថែរក្សាសួនច្បារជប៉ុនដែលមានសារៈសំខាន់ជាប្រវត្តិសាស្ត្រ។ នៅពេលធ្វើរបងឫស្សី លោកបានដាក់ឫស្សីបញ្ឈរតាមក្បួន ដើម្បីកុំឱ្យវាមិនត្រង់ផូរដោយវែខាងឆ្វេង ឬ ស្តាំ។ លោកបានសម្រេចចិត្តពីរបៀប*

*ចងខ្សែពួរខ្មៅ ដោយគណនាចន្លោះចំណាង និងអាំងតង់ស៊ីតេ(កំលាំង) ក្នុងចំណោមកត្តាផ្សេងទៀតក្នុងគោលបំណងធ្វើឱ្យមានតុល្យភាពទាំងមុខងារ និងភាពស្រស់ស្អាតនៃចំណងនោះ។*

<u>ទំព័រទី១៨៖</u>

## ចំណងមនុស្ស និងមនុស្ស និងការរស់នៅ ៖ ស្ពាន

ការស្ថាបនាស្ពានរបស់ជប៉ុន គឺជាបច្ចេកវិទ្យាឈានមុខមួយនៅលើពិភពលោក។ ការរក្សាភាពរឹងមាំក្នុងការប្រឈមមុខនឹងការលំបាកផ្សេងៗ ស្ពានបានធ្វើឱ្យក្តីសុបិន្តក្លាយជាការពិត ហើយបានភ្ជាប់ជីវិតរបស់ប្រជាជនរាប់មិនអស់នៅទូទាំងប្រទេសជប៉ុន។

*១. រូបភាពនៅខាងក្រោមស្ពាន ដែលការបង្ហាញពីរចនាបទដ៏ស្មុគស្មាញនៃសំណង់ឈើ ដែលអាចមើលឃើញបាន។*

*២. រូបភាពនៅពេលដែលឆ្លងកាត់ស្ពានជម្រាលដ៏ចោតមួយហើយ មានស្ពានដ៏ចោតមួយទៀតនៅចំពោះមុខ។*

*រូបភាពដោយ PIXTA*

### ស្ពានគីនតៃ (Kintai Bridge)

ស្ពានគីនតៃ(Kintai) គឺជាស្ពានដែលធ្វើពីឈើមានប្រវែងប្រហែល២០០ម៉ែត្រ និងទទឹង៥ម៉ែត្រ ឆ្លងកាត់ទន្លេនិស៊ិគិ (Nishiki) ក្នុងទីក្រុងអ៊ិវ៉ាគឹនិ(Iwakuni) ខេត្តយ៉ាម៉ាហ្គឹឈិ(Yamaguchi) ភាគខាងលិចប្រទេសជប៉ុន។ ផ្នែកទាំងបីនៅកណ្តាលមានរាងកោង។ ភាពឆើតឆាយនៃស្ពាននេះស្រដៀងនឹងរូបរាងខ្សែក្រវ៉ាត់ប្រពៃណីនៃសម្លៀកគីម៉ុណូ ស្ពាននេះក៏ត្រូវបានដាក់ឈ្មោះថា គីនតៃ (Kintai) ដែលមានន័យថា ខ្សែក្រវ៉ាត់មាស។ ឈើប្រណីតដែលមានគុណភាពចំនួន៦ប្រភេទត្រូវបានជ្រើសរើសយ៉ាងល្អិតល្អន់ និងដែកដែលធន់នឹងភាពច្រេះ ត្រូវបានប្រើយ៉ាងពិសេសសម្រាប់ការសាងសង់ ហើយវាត្រូវបានគេនិយាយថា គឺជាគំរូដ៏ល្អបំផុតនៃវិស្វកម្ម សូម្បីតែនៅក្នុងស្តង់ដារសាងសង់ស្ពានសម័យទំនើបក៏ដោយ។

ស្ពាននេះ គឺជាបច្ចេកវិទ្យាឈានមុខមួយ ដែលមានគោលបំណងយ៉ាងមុតមាំក្នុងការសាងសង់ស្ពានដែលអាចទប់ទល់នឹងចរន្តទឹកហូរខ្លាំង។ ចាប់តាំងពីអំឡុងឆ្នាំ១៦០០មក ប្រជាជនបានសាងសង់ស្ពាននៅទីនេះម្តងហើយម្តងទៀត ដោយសារតែត្រូវទឹកជំនន់ហូរយកទៅ។ ដើម្បីបង្កើតស្ពានដែលអាចទប់ទល់នឹងទំហំទឹកទន្លេ និងចរន្តទឹកហូរយ៉ាងលឿនបាន ពួកគេបានចាប់ផ្តើមស្រាវជ្រាវអំពីស្ពានដែលគ្មានសសរ ហើយក៏សម្រេចបានស្ពាន

ដូចដែលមានសព្វថ្ងៃនេះ  ដោយធ្វើកូនកោះចំនួន៤ ហើយមានជញ្ជាំងថ្មដែលត្រូវបានសាងសង់កាត់ទន្លេ ដើម្បីទ្រស្ពានទាំង៥។ សសរស្តម្ភត្រូវបានតំឡើងនៅសងខាងទន្លេដែលមានចរន្តទឹកខ្សោយ ហើយស្ពានកោងចំនួន៣ ដែលគ្មានសសរត្រូវបានសាងសង់នៅចំកណ្ដាល។ ស្ពានគីនតៃត្រូវបានបញ្ចប់នៅឆ្នាំ១៦៧៣ ក្រោយពីបានសាងសង់ប្រហែលជិតមួយទសវត្សរ៍។

<u>ទំព័រទី១៩៖</u>

ទោះជាយ៉ាងណាក៏ដោយ គ្រាន់តែមួយឆ្នាំក្រោយមក ស្ពាននេះក៏ត្រូវទឹករលកបកទៅបាត់។ បន្ទាប់មក គ្រឹះនៃសសរជញ្ជាំងដែលធ្វើពីថ្មត្រូវបានធ្វើឱ្យប្រសើរឡើងវិញភ្លាមៗ ហើយស្ពានដ៏រឹងមាំមួយនេះក៏ត្រូវបានសាងសង់ឡើង។ បន្ទាប់ពីនោះមក ស្ពាននេះបានតស៊ូអស់រយៈពេល២៧៦ឆ្នាំ រហូតដល់ជួបនឹងព្យុះទីហ្វុងដ៏ខ្លាំងមួយ បានបោកបក់យកវាទៅម្តងទៀតនៅឆ្នាំ១៩៥០។ ស្ពានគីនតៃ ត្រូវបានកសាងឡើងវិញនៅឆ្នាំ១៩៥៣ នៅតែមានជាមួយយើងសព្វថ្ងៃនេះ ដែលអាចសន្មត់នូវអាយុកាលគិតចាប់ពីពេលសាងសង់ដំបូងមក គឺប្រមាណជា៣៥០ឆ្នាំមុន។

ធម្មជាតិដ៏សំបូរបែបព័ទ្ធជុំវិញសំណង់ដ៏ស្រស់ស្អាតនៃស្ពានក្ការប្រាំនេះ បានផ្តល់នូវទេសភាពដ៏ស្រស់ស្អាតគ្រប់រដូវទាំងបួន គឺផ្កាសាគូរ៉ារីកនៅរដូវផ្ការីក កាំជ្រួចនៅរដូវក្តៅ ការប្តូរពណ៌ស្លឹកឈើនៅរដូវស្លឹកឈើជ្រុះ និងទេសភាពព្រិលនៅរដូវរងា។

## ស្ពានដ៏ល្បីល្បាញទាំងបីរបស់ជប៉ុន

ស្ពានគីនតៃ(Kintai) ត្រូវបានគេនិយាយថាជាស្ពានមួយក្នុងចំណោមស្ពានដ៏ល្បីល្បាញបំផុតទាំងបីនៅក្នុងប្រទេសជប៉ុនរួមជាមួយស្ពានម៉ិហ្គាណិ(Megane)មានន័យថា "ស្ពានវែនតា" នៅខេត្តណាហ្គាសាគិ(Nagasaki) និងស្ពាននិហុនបាស៊ិ (Nihonbashi) នៅតូក្យូ(Tokyo)។

*១. ស្ពានគីនតៃ ត្រូវបានដាក់ភ្លើងបំភ្លឺនៅពេលយប់ ដែលផ្តល់នូវទិដ្ឋភាពដូចវេទមន្ត។*

*២. ស្ពានម៉ិហ្គាណិ គឺជាកន្លែងទស្សនាដ៏សំខាន់មួយនៅណាហ្គាសាគិ។*

*៣. នៅពេលសាងសង់ស្ពាននិហុនបាស៊ិ គឺជាចំណុចចាប់ផ្តើមនៃផ្លូវធំៗ ចំនួន៥។ ការងាររើផ្លូវល្បឿនលឿនខាងលើនេះគ្រោងនឹងបញ្ចប់នៅឆ្នាំ២០៤០។*

<u>ទំព័រទី២០៖</u> **ដំណើរកំសាន្តជាក់ស្តែងទូទាំងប្រទេសជប៉ុន**

## ទីតាំងនានានៃ អេន-មឹស៊ឹប៊ិ( En-musubi )

ពាក្យជប៉ុន"អេន(en)" មានន័យថាចំណងនិស្ស័យ ការទំនាក់ទំនង ឬ ការភ្ជាប់ទំនាក់ទំនងដូចជាមនុស្ស និង ព្រឹត្តិការណ៍ជាដើម។ លោកអ្នកមានបំណងស្វែងរកដៃគូស្នេហាដ៏អស្ចារ្យ ឬការងារល្អៗ? លោកអ្នកចង់ឲ្យក្រុមគ្រួសារ ឬ មិត្តភក្តិតែងតែមានទំនាក់ទំនងល្អជានិច្ច? តំបន់ទេសចរបែប "អេន-មឹស៊ឹប៊ិ (en-musubi)" របស់ប្រទេសជប៉ុន ត្រូវបានគេស្គាល់ជាលក្ខណៈប្រពៃណីសម្រាប់ការប៉ងប្រាថ្នារឿងទាំងនោះឲ្យក្លាយជាការពិត និងសម្រាប់ការព្យាយាមធ្វើឲ្យវិជ្ជមាន នៃ"អេន"។ តោះទៅទស្សនាតំបន់ទេសចរណ៍ "អេន-មឹស៊ឹប៊ិ"!

### ព្រះវិហារហាគឹតុ (Hakuto Shrine) នៅទីក្រុងតុតតុរិ (Tottori)

នៅក្នុងកុជិគិ (Kojiki) ដែលជាស្នាដៃអក្សរសិល្ប៍ចាស់ជាងគេរបស់ជប៉ុន មានរឿងព្រេងនិទានមួយថា ទន្សាយពណ៌សដែលរងរបួសត្រូវបានព្រះជួយសង្គ្រោះ ហើយដានជើងរបស់វាមានពាសពេញ ហាគឹតុ(Hakuto) (មានន័យថា" ទន្សាយពណ៌ស")។ ហើយទីកន្លែងនេះ ក៏ត្រូវបានគេស្គាល់ថាជាទិដ្ឋភាពក្នុងរឿងស្នេហាចំណាស់ជាងគេបំផុតនៅក្នុងប្រទេសជប៉ុនផងដែរ។

### ស្ពានម៉ិហ្គាណិ (Megane Bridge) នៅទីក្រុងណាហ្គាសាគិ (Nagasaki)

ស្ពានម៉ិហ្គាណិ(Megane Bridge) (មានន័យថា" ស្ពានវ៉ែនតា") គឺជាស្ពានថ្មដំបូងគេបង្អស់របស់ប្រទេសជប៉ុនដែលត្រូវបានសាងសង់ក្នុងឆ្នាំ១៦៣៤។ វាត្រូវបានគេដាក់ឈ្មោះដូច្នេះ ដោយសារតែការឆ្លុះត្រឡប់នឹងទន្លេ មើលទៅស្រដៀងវ៉ែនតា។នៅពេលលោកអ្នកស្វែងរកដុំថ្មដែលមានរាងបេះដូងនៅតាមច្រាំងថ្មក្បែរស្ពាននេះឃើញ គេនិយាយថាបំណងប្រាថ្នានឹងក្លាយជាការពិត។

### កោះឈិរិនហ្គាស៊ិម៉ា (Chiringashima) នៅទីក្រុងអ៊ិប៊ឹស៊ឹគិ(Ibusuki)

កោះឈិរិនហ្គាស៊ិម៉ា (Chiringashima) គឺជាកោះដែលគ្មានមនុស្សរស់នៅ ស្ថិតនៅឈូងសមុទ្រខាហ្គុស៊ិម៉ា (Kagoshima)។ នៅពេលជំនោរទាប ចាប់ពីខែមីនា ដល់ខែតុលាប៉ុណ្ណោះ ដែលមានផ្លូវខ្សាច់ប្រវែងប្រហែល៨០០ ម៉ែត្រ លេចចេញមកដើម្បីភ្ជាប់ផ្លូវទៅកោះដែលធ្វើឱ្យយើងអាចដើរឆ្លងកាត់បាន។ ដូច្នេះវាត្រូវបានគេស្គាល់ថាជាកោះអេន-មឹស៊ឹប៊ិ (en-musubi)។

<u>ទំព័រទី២១៖</u>

**បឹងតុយ៉ុនិ (Toyoni Lake) នៅស្រុកហូរីហ្ស៊ូមិ (Horizumi)**

បឹងនេះត្រូវបានគេស្គាល់ថាជាកន្លែងទស្សនាសម្រាប់ផ្សាភ្ជាប់ទំនាក់ទំនងស្នេហា។ ព័ទ្ធជុំវិញដោយព្រៃបុរេប្រវត្តិដ៏អស្ចារ្យ ទិដ្ឋភាពពីលើអាកាសបង្ហាញថាបឹងនេះមានរាងដូចបេះដូង។

**ស្រះប៊ិសាម៉ុន-នឹម៉ា(Bishamon-numa Pond) នៅស្រុកយ៉ាម៉ា (Yama)**

ផ្នែកមួយនៃស្រះហ្គូស៊ិគិ-នឹម៉ា(Goshiki-numa) (មានន័យថា ស្រះប្រាំពណ៌) ដែលជាក្រុមស្រះ និងបឹង ក្នុងនោះស្រះប៊ិសាម៉ុន-នឹម៉ា មានប្រជាប្រិយភាព ដោយសារវាជាផ្ទះរបស់ត្រីគល់រាំងពណ៌ស ដែលមានរូបបេះដូងក្រហមនៅចំហៀងខ្លួន ដែលត្រូវបានគេនិយាយថា នាំមកនូវសុភមង្គលដល់អ្នកមានសំណាងដែលបានឃើញវា។

**ព្រះវិហារកាវ៉ាហ្គូអិ (Kawagoe Hikawa Shrine) នៅទីក្រុងកាវ៉ាហ្គូអិ (Kawagoe)**

ជារៀងរាល់ឆ្នាំ នៅខែកក្កដា និងសីហា មានកណ្ដឹងខ្យល់អេដុ(Edo Fūrin) ចំនួនជាង២.០០០ បានបន្លឺឡើងជាមួយនឹងសំឡេងកណ្ដឹងដ៏ស្រស់ស្រាយរបស់ពួកវា។ នៅក្នុងពិធីមង្គលការ មានពិធីពិសេសមួយសម្រាប់កូនក្រមុំ និងកូនកំលោះ ដែលត្រូវចងខ្សែក្រហមពិសេសដែលបង្ហាញពីជោគវាសនារបស់គូស្នេហ៍ជុំវិញម្រាមកូនដៃរបស់ពួកគេ។

**កន្លែងមើលទេសភាពនៃកោះមិអិស៊ិម៉ា (Mieshima Observatory) នៅស្រុកវ៉ាតារ៉ៃ (Watarai)**

ទិដ្ឋភាពដ៏អស្ចារ្យនៃឆ្នេររាងបេះដូងដ៏ស្រស់ស្អាតនៃស្រះកាសារ៉ាហ្គិ(Kasaragi) គឺផ្ដាច់មុខសម្រាប់វេទិកាទស្សនាទេសភាពកោះមិអិស៊ិម៉ា នៅក្នុងឧទ្យានជាតិ អ៊ិសិ-ស៊ិម៉ា(Ise-Shima)។ ទីកន្លែងនេះក៏ត្រូវបានគេហៅថាជាកន្លែងពិសេសមួយសម្រាប់គូស្នេហ៍ដែលអាចចាក់សោរហៅថា "សោរនៃសម្បថស្នេហា" នៅលើកន្លែងចាក់សោរនៅទីនោះ។

ទំព័រទី២២៖ **រសជាតិនៃប្រទេសជប៉ុន៖ ពេលវេលាទទួលទាន!** ⑱

## ភ្ជាប់នូវជួនពរលឹបដ៏ស្រស់ស្អាត

**ឆាគិន-ហ្ស៊ឹស៊ិ**( Chakin-zushi )

ឆាគិន-ហ្ស៊ឹស៊ិ (Chakin-zushi) ត្រូវបានធ្វើឡើងដោយបាយលាយបញ្ចូលគ្នាជាមួយគ្រឿងផ្សំផ្សេងៗ ហើយខ្ចប់វាជាមួយពងមាន់ចៀនស្តើង។ ឈ្មោះនេះបានមកពីពាក្យ ឆាគិន(Chakin) ដែលជាក្រណាត់រាងចតុកោណសម្រាប់ប្រើជូតពែងតែក្នុងពិធីលៀងតែជប៉ុន ទើបបានបំផុសគំនិតរូបពងមាន់ចៀនស្តើងជារាងបែបនេះ។

គេនិយាយថាប្រហែលមួយសតវត្សរ៍មកហើយ ដែលចុងភៅម្នាក់ដែលបម្រើគ្រួសារអភិជនបានចាប់ផ្តើមដំបូងសម្រាប់អាហារនៅក្នុងពិធីលៀងតែជប៉ុន ហើយបន្ទាប់មកវាក៏បានក្លាយជាការពេញនិយម។

ឆាគិន ហ្ស៊ឹស៊ិ ត្រូវបានធ្វើឡើងដោយបាយលាយជាមួយទឹកខ្មេះ អំបិល និងស្ករស។ បន្ទាប់មកបន្ថែមគ្រឿងផ្សំដ៏មានរសជាតិឈ្ងុយឆ្ងាញ់ បានមកពីលើភ្នំ និងសមុទ្រដោយលាយជាមួយបាយនោះ មានដូចជាកាមភ្យ៉ូ(kampyo) (ឃ្លោកស្ងួតជាសរសៃៗ) ផ្សិតស៊ិតាកិ (shiitake) ត្រូវហាន់ជាបន្ទះស្តើងៗ ហើយច្របល់ជាមួយល្ង សាច់ត្រីតៃ (tai)អាំង និងសាច់ក្តាមជាដើម។

*ស៊ុតដែលបានក្រឡុងយ៉ាងពិសេស ត្រូវបានប្រើដើម្បីធានាបាននូវពណ៌ស្រស់ស្អាត ហើយរសជាតិក៏ឆ្ងាញ់យ៉ាងពិសេស។*

*ស៊ុតចៀនស្តើងដែលងាយរហែកត្រូវបានគេខ្ចប់យ៉ាងល្អិតល្អន់ និងចងជាមួយខុមប៊ឹ (kombu)។*

*មេចុងភៅ លោក សាសាគី ហ៊ីរ៉ូមិ (Sasaki Hiromi) រក្សានូវរសជាតិបុរាណ និងប្រពៃណី។*

*សហការដោយ៖ អាកាសាកា យឹស្យ៉ូគឹ (AkasakaYushoku)*

<u>ទំព័រទី២៣៖</u>

បាយត្រូវបានធ្វើឡើងជារាងដូចបាល់តូចមួយដែលមានការប្រែប្រួលតាមរដូវ។ នៅរដូវផ្ការីកដល់រដូវក្ដៅវាត្រូវគុបតែងពីលើដោយមានគ្រាប់សណ្ដែកដែលមានរសជាតិផ្អែម និងនៅរដូវស្លឹកឈើជ្រុះគឺមានផ្លែកៅឡាក់ស្ងោរយ៉ាងឈ្ងុយឆ្ងាញ់។ បន្ទាប់មកទើបខ្ចប់ជាមួយពងមាន់ចៀនស្តើង រួចចងដោយកុមប៊ឺ(kombu)(ពពួកសារ៉ាយសមុទ្រ) ដើម្បីកុំអោយបាយហៀរចេញ។ នៅពេលដែលវាមានរាងដូចក្នុងរូបភាពនេះហើយ ឆាគិន ហ្ស៊ីស៊ិធ្វើរួចរាល់ជាស្ថាពរ។

សព្វថ្ងៃនេះមានការរៀបចំ និងការធ្វើបទបង្ហាញផ្សេងៗគ្នាសម្រាប់ឆាគីន ហ្សូស៊ិ ហើយនៅក្នុងឱកាសការជួបជុំជាមួយគ្រួសារ និងមិត្តភក្តិ រូបមន្តចម្អិនអាហារនេះច្រើននិយមធ្វើទៅតាមការចូលចិត្តរៀងៗខ្លួន។ គ្រឿងផ្សំដែលលាយជាមួយបាយ និងរបៀបទទួលទានគឺត្រូវបានរៀបចំឡើងតាមចំណង់ចំណូលចិត្ត។ អាហារមួយមុខនេះ នាំមកនូវស្នាមញញឹមលើតុអាហារ។

*រូបរាងឆើតឆាយ ដែលមានចំណងដោយដើមសណ្ដែកជប៉ុន ដែលវាបានរំលឹកដល់ខ្សែក្រវ៉ាត់របស់សម្លៀកបំពាក់គិម៉ូណូ ហើយចំណងនេះមានបំណងការពារកុំឱ្យហៀរបាយចេញក្រៅ។ អាហារនេះពេញនិយមសម្រាប់ឱកាសពិសេសដូចជា ពិធីបុណ្យហ៊ីណាម៉ាស៊ឺរិ (ពិធីបុណ្យក្មេងស្រី ឬ កុមារី) ថ្ងៃទី៣ ខែមីនា ជាពិធីបុណ្យបួងសួងសម្រាប់ការលូតលាស់ប្រកបដោយសុខភាពល្អរបស់ក្មេងស្រី។*

<u>ទំព័រទី២៤៖</u> **ដើរកំសាន្តនៅប្រទេសជប៉ុន ⑲**

## កន្លែងដែលមនុស្ស ប្រវត្តិសាស្ត្រ និងធម្មជាតិត្រូវបានបញ្ចូលគ្នា

### នីកក្វ(Nikko)

នីកក្វ ត្រូវបានគេស្គាល់ថាជាកន្លែងទីសក្ការបូជា និងព្រះវិហារដែលជាបេតិកភណ្ឌពិភពលោក ព្រមជាមួយទិដ្ឋភាពដែលអំណោយផលដោយទេសភាពធម្មជាតិខៀវស្រងាត់។

យើងនឹងទទួលបាននូវសំឡេងទឹកហូរធ្លាក់តាមជ្រលងដងអូរប្រស្រាចយ៉ាងថ្លាឆ្វង់ ហាក់បីដូចជានៅពេលដែលយើងកំពុងដើរកាត់ព្រៃភ្នំ។

ស្ថិតនៅភាគពាយ័ព្យនៃខេត្តតូឈិហ្គិ(Tochigi) ទីក្រុងនីកក្វ បានទទួលភ្ញៀវទេសចរជាតិ និងអន្តរជាតិជាង១០លាននាក់ជារៀងរាល់ឆ្នាំ។

ការប្រែប្រួលកម្ពស់ភ្នំមានការខុសគ្នាខ្លាំងនៅនីកកូ ដែលមានកម្ពស់ចាប់ពី២០០-៥០០ម៉ែត្រនៅតំបន់កណ្តាល ហើយឡើងដល់២.៥៧៨ម៉ែត្រនៅលើភ្នំស៊ិរ៉ាណិ(shirane) ដែលជាកំពូលភ្នំខ្ពស់បំផុតនៃជួរភ្នំនីកកុ។ ដោយសារតែហេតុនេះហើយបានជាផ្កាសាគូរ៉ារីក និងដើមឈើនារដូវស្លឹកឈើជ្រុះផ្លាស់ប្តូរពណ៌ក្នុងល្បឿនគួរឱ្យភ្ញាក់ផ្អើល ដែលអនុញ្ញាតឱ្យយើងបានឃើញផ្ការីក និងទិដ្ឋភាពនៃរដូវស្លឹកឈើជ្រុះបានយូរ នៅទីតាំងផ្សេងៗគ្នាក្នុងតំបន់នីកកូនេះ។

ថ្វីបើស្ថិតនៅក្នុងតំបន់ទីប្រជុំជនក៏ដោយ ក៏ភ្ញៀវទេសចរអាចរីករាយដំណើរកំសាន្តប្តូរពេលវេលាទៅកាន់អតីតកាលដ៏សែនឆ្ងាយនៅលើដងផ្លូវអមសងខាងដោយដើមស្រល់នៅនីកកូ។ សរុបផ្លូវដើរទាំងបី (ផ្លូវនីកកូ(nikko), ផ្លូវរ៉េហេស៊ិ(reheshi), ផ្លូវអៃហ្ស៊ុ-និស៊ិ(aizu-nishi)) មានប្រវែងប្រហែល ៣៧គីឡូម៉ែត្រ និងមានដើមស្រល់ធំៗប្រហែល១២.០០០ដើមនៅសងខាងផ្លូវ។ វាត្រូវបានចុះក្នុងសៀវភៅកំណត់ត្រាហ្គីណេសពិភពលោកថា ជាផ្លូវដែលមានដើមឈើអមសងខាងវែងជាងគេ។ ទោះបីជារយៈពេលដ៏សែនយូរប្រហែល៤០០ឆ្នាំគិតចាប់តាំងពីពេលដាំដើមឈើទាំងនោះហើយរហូតមកដល់ពេលនេះក៏ដោយ ក៏នៅលើផ្លូវទាំងបីនោះនៅតែហាក់បីដូចជាធ្វើឲ្យយើងបានលឺខ្យល់ដកដង្ហើមរបស់មនុស្សកាលពីជំនាន់នោះ តាមរយៈការទៅដល់តំបន់រមណីយដ្ឋានព្រះវិហារនីកកូ តូស្យ៉ូហ្គឹ (Nikko Toshogu)ដែលទាំងអស់នេះហើយ គឺជានិមិត្តសញ្ញារបស់នីកកូ(Nikko)។

តំបន់រមណីយដ្ឋានព្រះវិហារនីកកូ តូស្យ៉ូហ្គឹ ផ្តើមដោយព្រះវិហារ និងវត្តនៅនីកកូ ក្រៅពីនេះក៏មាន ព្រះវិហារហ៊្វឹតារ៉ាសាន-ជិនចា (Nikko Futarasan-jinja) និង១០៣វិហារក្នុងវត្តនីកកុហ្សាន រីនណុជិ (Nikkozan Rinnoji) ព្រមទាំងបេតិកភណ្ឌផ្សេងទៀត(ទស្សនីយភាពវប្បធម៌) ដែលនៅជុំវិញនោះ ។

*- ផ្លូវអមសងខាងដោយដើមស្រល់នៅនីកកូ*

*- រូបចម្លាក់នាគពណ៌សលើខ្លោងទ្វារយ៉ូមេម៉ុន* (Yomeimon)

*ស្វាដែលបង្ហាញកាយវិការបី គឺជារូបភាពចម្លាក់ដែលចេញពីសុភាសិតជប៉ុនថា "មិនមើល មិននិយាយ មិនស្តាប់រឿងដែលអាក្រក់" ។*

<u>ទំព័រទី២៥៖</u>

ទាំងនេះត្រូវបានបង្កើតឡើងដោយការរួមបញ្ចូលនៃមនោសញ្ចេតនារបស់មនុស្សចំពោះធម្មជាតិ ជាមួយនឹងអគារព្រះវិហារដែលត្រូវបានសាងសង់ដោយទ្រព្យសម្បត្តិ និងអំណាចដ៏ខ្លាំងក្លារបស់ក្រុមគ្រួសារតុគឹហ្គាវ៉ា ស្យ៉ូហ្គឹន (Tokugawa Shogun) (កម្លាំងស្នូលនៃរដ្ឋាភិបាលសម័យអេដុនៃមេដឹកនាំយោធាមកពីគ្រួសារតុគឹហ្គាវ៉ា ហៅថា អេដូ ស្យ៉ូហ្គុណាតិ(Edo Shogunate) ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៦០៣ ដោយតុគឹហ្គាវ៉ា អ៊ិអិយ៉ាស៊ឺ (Tokugawa Ieyasu) ហើយបន្តរហូតដល់ឆ្នាំ១៨៦៨)។

ខ្លោងទ្វារយ៉ូមេម៉ុន(Yomeimon) ដែលតុបតែងយ៉ាងស្រស់ស្អាត និងពោរពេញដោយពណ៌ស្រស់ឆើតឆាយ បានទាក់ទាញភ្នែកជាពិសេស នៅតំបន់រមណីយដ្ឋានព្រះវិហារនីកក្កូ តូស្យ៉ូហ្គឹ។ វាត្រូវបានសាងសង់ឡើងនៅឆ្នាំ១៦៣៦ និងបានប្រមូលផ្តុំដោយជាងដែក និងសិប្បករម្រ័ក្សណ៍ខ្មុកដ៏មានជំនាញកំពូលៗនៅពេលនោះ។ ការដែលបានឃើញចម្លាក់ និងគំនូរសត្វជាច្រើន គឺជាផ្នែកដ៏រីករាយមួយ នៃតំបន់រមណីយដ្ឋានព្រះវិហារនីកក្កូ តូស្យ៉ូហ្គឹ។ គ្រាន់តែចម្លាក់ដ៏ប្រណិតនៃរូបមនុស្ស និងសត្វ គឺមានជាង៥០០។

នៅជិតច្រកចូលព្រះវិហារ និងវត្តនីកក្កូ អ្នកទេសចរក៏អាចទទួលអារម្មណ៍បែបសម័យទំនើបដោយចូលខ្លួនទៅក្នុងបរិយាកាសដ៏ស្រស់ស្រាយនៅចំកណ្តាលទេសភាពនៃវិហារប្រវត្តិសាស្ត្រជាច្រើន រួមទាំងសណ្ឋាគារប្រវត្តិសាស្ត្រដែលបានបង្កើតឡើងក្នុងឆ្នាំ ១៨៧៣ ជាសណ្ឋាគារបែបរមណីយដ្ឋានដំបូងគេនៅប្រទេសជប៉ុន និងហាងលក់វត្ថុអនុស្សាវរីយ៍ ដែលមានវត្ថុសិប្បកម្មប្រពៃណីរបស់នីកក្កូ ព្រមទាំងផលិតផលពិសេសប្រចាំតំបន់ផងដែរ។

*- ខ្លោងទ្វារយ៉ូមេម៉ុន(Yomeimon) នៅតំបន់រមណីយដ្ឋានព្រះវិហារនីកក្កូ តូស្យ៉ូហ្គឹ (Nikko Toshogu) ដែលជានិមិត្តរូបនៃនីកក្កូ(Nikko)*

*- ណិមឺរិណិកុ (Nemurineko ឆ្មាកំពុងដេក) នៅខ្លោងទ្វារសាកាស៊ិតាម៉ុន (Sakashita-mon) គឺជារូបរាងនៃការគេងរបស់ឆ្មានៅក្រោមពន្លឺព្រះអាទិត្យ ដែលជានិមិត្តរូបនៃការបួងសួងសម្រាប់សន្តិភាព។*

*- " បាយការីយៈពេលរយឆ្នាំ" បង្កើតឡើងវិញនូវរសជាតិប្រពៃណីនៃរូបមន្តដ៏អាថ៌កំបាំង។*

*- នៅតុទទួលភ្ញៀវយើងអាចទទួលបាននូវអារម្មណ៍ជាប្រវត្តិសាស្ត្រនៃសណ្ឋាគារនីកក្កូកាណាយ៉ា(Nikko Kanaya) ដែលមានអាយុកាលវែង។*

<u>ទំព័រទី២៦៖</u>

ជម្រាលអ៊ីរ៉ូហាហ្សាកា(Irohazaka) ជាផ្លូវទេសចរណ៍ដែលតភ្ជាប់ទីប្រជុំជននីកកូ និងអុគឺនីកកូ(Okunikko) ហើយមានប្រជាប្រិយភាពយ៉ាងខ្លាំងចំពោះទេសភាពគួរជាទីគយគន់ក្នុងរដូវស្លឹកឈើជ្រុះ។ វា គឺជាផ្លូវគួ ដែលមួយចំហៀងឡើង មួយចំហៀងទៀតចុះ ហើយមានផ្លូវខ្សែកោងសរុបចំនួន៤៨។ នៅទូទាំងនីកកូ មានទឹកធ្លាក់ជាច្រើនដែលផ្តល់នូវភាពរីករាយក្នុងការទស្សនានៃទិដ្ឋភាពផ្សេងទឹក និងធម្មជាតិដ៏ស្រស់ស្អាត។ ជាពិសេសគឺ ទឹកធ្លាក់កិហ្គុន(Kegon) ដែលមានភាពល្បីល្បាញ ដោយទឹកបឹងជឺហ្សេនជិ(Chuzenji) បានធ្លាក់ហូរចុះក្រោមតាមច្រាំងថ្មមានកម្ពស់៩៧ម៉ែត្រ ដែលជាទស្សនីយភាពដ៏អស្ចារ្យ។ នៅជុំវិញតំបន់ដីសើមនៃខ្ពង់រាបសេនចូហ្គាហារា(Senjogahara)លាតសន្ធឹងលើផ្ទៃដី៤០០ហិកតា។ ទីកន្លែងដើម្បីទស្សនាត្រូវបានរៀបចំឡើងជាច្រើនកន្លែងផ្សេងៗគ្នា ដែលអ្នកទេសចរអាចទស្សនានូវបរិស្ថានធម្មជាតិដ៏អស្ចារ្យ និងសម្បូរបែប។

ប្រសិនបើលោកអ្នកចង់រីករាយជាមួយអាហារឆ្ងាញ់របស់នីកកូ យើងសូមណែនាំពពុះសណ្តែក ដែលភាសាជប៉ុនហៅថាយឺបា(yuba)។ យឺបា ត្រូវបានធ្វើឡើងពីទឹកសណ្តែកសៀងដែលពុះនៅលើផ្ទៃឆ្នាំងកើតជាបន្ទះ ហើយយើងស្រង់វាឡើងមក។ អាហារដ៏ឆ្ងាញ់នេះ បានរីកសាយភាយពាសពេញវត្ត និងព្រះវិហារនៅទីក្រុងនីកកូ ព្រោះវាជាប្រភពអាហារដ៏មានប្រូតេអ៊ីន និងមានតម្លៃមួយសម្រាប់ព្រះសង្ឃ នូវការចៀសវាងការឆាន់ត្រី និងសាច់។ យឺបារបស់នីកកូ គឺក្រាស់ និងងាយស្រួលក្នុងការទទួលទាន។ វាត្រូវបានគេបរិភោគឆៅជាមួយទឹកជ្រលក់ ឬ ស្ងោរ ឬចៀន ឆា បំពងក៏បាន។ នីកកូក៏ត្រូវបានគេស្គាល់ថាជាកន្លែងពិសិដ្ឋសម្រាប់ទឹកកកឈូស(Kakigori)ផងដែរ។ ទឹកកកឈូសធ្វើចេញពីទឹកកកធម្មជាតិដែលមានគុណភាពខ្ពស់ដែលត្រូវបានកកយឺតៗដោយភាពត្រជាក់ក្នុងរដូវរងា ធ្វើឲ្យយើងអាចរីករាយពេញមួយឆ្នាំជាមួយនឹងរសជាតិស្រទន់របស់វា។

*ធម្មជាតិនៃរដូវទាំងបួនអាចរីករាយនៅបឹងជូហ្សេនជិ(Chuzenji)។*

*ជម្រាលអ៊ីរ៉ូហាហ្សាកា(Irohazaka) គឺជាកន្លែងពេញនិយមនៅរដូវស្លឹកឈើជ្រុះ។*

*យឺបា(yuba) (ពពុះសណ្តែក) អាហារនៅហាងតាកៃយ៉ា(Takaiya) ជាភោជនីយដ្ឋានដែលមានប្រវត្តិជាង២០០ឆ្នាំ។*

*រូបខាងលើ៖ ទឹកធ្លាក់កិហ្គុន(Kegon) ធ្លាក់មកលឺសំឡេងយ៉ាងទ្រហឹងអឺងកង។*

*រូបខាងក្រោម៖ ខ្ពង់រាបសេនចូហ្គាហារា(Senjogahara) ត្រូវបានចុះបញ្ជីអនុសញ្ញារ៉ាមសារ* ផងដែរ*

**អនុសញ្ញាស្តីពីតំបន់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិជាពិសេសជាជម្រកសត្វស្លាបទឹក។*

<u>ទំព័រទី២៧៖</u>

ភាពរំជើបរំជួលនៃការជិះទូកកម្សាន្តតាមដងទន្លេគិនឹហ្គាវ៉ា(kinugawa) ដែលមានទឹកហូរយ៉ាងលឿន ព្រមជាមួយសម្រស់ដ៏អស្ចារ្យនៃជ្រលងភ្នំព័ទ្ធជុំវិញក៏បានបង្កើតជាភាពរីករាយផងដែរ។ មិនត្រឹមតែប៉ុណ្ណឹងទេ តំបន់នេះក៏សម្បូរទៅដោយអុនសេន(onsen ប្រភពទឹកក្តៅធម្មជាតិ) ជាច្រើន។ ភាពសម្បូរបែបពោរពេញទៅដោយធម្មជាតិទាំងនេះ នឹងផ្តល់ឲ្យយើងនូវភាពកក់ក្តៅ និងអារម្មណ៍ស្រស់ស្រាយជាក់ជាពុំខាន។

សិប្បករមកពីទូទាំងប្រទេសជប៉ុន បានមកនីកកូដើម្បីសាងសង់វត្ត និងព្រះវិហារជាច្រើន ហើយស្នាដៃដ៏វិសេសវិសាលរបស់ពួកគាត់បានចាក់ឫសក្នុងតំបន់នេះ ក្នុងទម្រង់ជាសិប្បកម្មប្រពៃណីមានជម្រៅដ៏ប្លែកពិសេស។

នីកកូបុរិ (Nikko-bori ការឆ្លាក់ឈើរបស់នីកកូ) ត្រូវបានឆ្លាក់ដោយតាមលំហូរខ្សែកោងនៃកាំបិតឆ្លាក់ពិសេសជាមួយនិងម្រ័ក្សណ៍ខ្មុកដ៏ពិសេសដែលមានតែមួយគត់របស់នីកកូ ដែលធ្វើឱ្យសាច់ឈើកាន់តែមានភាពស្រស់ស្អាតបំផុត។

នីកកូហ្គិតា (Nikko-geta ស្បែកជើងឈើរបស់នីកកូ) ត្រូវបានធ្វើពីហ្គិតា(geta) ជាស្បែកជើងឈើប្រពៃណីជប៉ុន ហើយភ្ជាប់ទ្រនាប់ពីលើដោយហ្សូរិ(zori) ជាស្បែកជើងចំបើងដែលត្រូវបានពាក់នៅពេលចូលទៅក្នុងវត្ត ឬ ព្រះវិហារ។ ផ្ទៃស្បែកជើងហ្សូរិ ត្រូវបានត្បាញពីសំបកឫស្សី។ វាត្រូវបានគេផលិតឡើងដើម្បីការពារការដើររអិលដោយសារព្រិល និងនៅលើផ្លូវឡើងទួលជាច្រើននៅនីកកូ។

នីកកូ គឺជាគោលដៅទេសចរណ៍ដ៏ល្បីល្បាញរបស់ប្រទេសជប៉ុន។ វាស្ថិតនៅទីតាំងដែលផ្តល់ភាពងាយស្រួលអាចឲ្យយើងធ្វើដំណើរកំសាន្តវិលល្ងាចបានពីតូក្យូដែលជារាជធានីរបស់ប្រទេសជប៉ុនបានយ៉ាងងាយ នេះហើយគឺជាហេតុផលមួយនៃប្រជាប្រិយភាពរបស់នីកកូ។

*ទឹកក្តៅធម្មជាតិអុគឹគិនឹ(Okukinu Onsen)*

*ជិះទូកតាមដងទន្លេគិនឹហ្គាវ៉ា(Kinugawa) យ៉ាងរីករាយ*

*ចម្លាក់ឈើ* នីកកូបុរិ (Nikko-bori)

ស្បែកជើងឈើ នីកកូ (Nikko-geta)

*ទឹកកកឈូសដែលមានរសជាតិឈ្ងុយឆ្ងាញ់ ធ្វើពីទឹកកកធម្មជាតិស្តើងៗ និងផ្លែស្ត្របឺរីពិសេសក្នុងស្រុកដែលត្រូវបានគេរម្ងាស់យ៉ាងផ្អែមហើយបញ្ចូលគ្នាជាមួយទឹកកក់ ដែលចូលជាតិគ្នាដ៏ល្អឥតខ្ចោះ។*

***ផែនទីនីកកូ***

*១. តំបន់រមណីយដ្ឋានព្រះវិហារនីកកូ តូស្យ៉ូហ្គូ (Nikko Toshogu)*

*២. សណ្ឋាគារនីកកូកាណាយ៉ា(Nikko Kanaya)*

*៣. ផ្លូវអមសងខាងដោយដើមស្រល់នៅនីកកូ*

*៤. ទឹកធ្លាក់កិហ្គុន(Kegon)*

*៥. ទឹកក្តៅធម្មជាតិអុគឹគិនឹ(Okukinu Onsen)*

*៦. ខ្ពង់រាបសេនចូហ្គាហារា(Senjogahara)*

*៧. ជម្រាលអ៊ិរ៉ូហាហ្សាកា(Irohazaka)*

*ការធ្វើដំណើរ៖*

*ទីក្រុងតូក្យូ(Tokyo) (៥០នាទី ដោយរថភ្លើងស៊ីនកាន់សេន(Shinkansen)) ⇒ អ៊ុត្សឹណូមិយ៉ា (Utsunomiya) (ប្រហែល ៥០ នាទីដោយខ្សែរថភ្លើង JR Nikko Line) ⇒ ស្ថានីយរថភ្លើង ជេ អ នីកកូ (JR Nikko Station)*

*អាសាគឹសា(Asakusa) (ប្រហែល២ម៉ោង ដោយរថភ្លើងតុប៊ឹគុកគ្សឹ(Tobu Limited Express) ⇒ ស្ថានីយរថភ្លើងតុប៊ឹនីកកូ (Tobu Nikko Station)*

*ទំនាក់ទំនងព័ត៌មាន៖*

*សមាគមន៍ទេសចរណ៍ក្រុងនីកកូ (Nikko City Tourism Association) [https://www/visitnikko/jp/en/](https://www/visitnikko/jp/en/)*

ទំព័រទី២៨៖

## **វត្ថុអនុស្សាវរីយ៍របស់ជប៉ុន ⑳**

### **សម្លៀកបំពាក់ថូផ្កា៖** ដបដាក់ផ្កាយ៉ាងទាក់ទាញត្រូវបានធ្វើឡើងពីក្រណាត់ត្បាញដ៏ស្រស់ស្អាត

យើងទទួលបានអារម្មណ៍នៃការផ្លាស់ប្តូររដូវជាមួយនឹងការតុបតែងផ្កា។ យើងអាចរីករាយបានគ្រប់ពេលជាមួយដបផ្កាដ៏ទាក់ទាញ ដែលបំផុសគំនិតចេញពីសម្ភារៈដែលប្រើនៅក្នុងកាកិជិគឹ(kakejiku) (រមូរសម្រាប់តាំងព្យួរជញ្ជាំងរបស់ជប៉ុន) ។ ទោះបីជាយើងមិនមានថូពិសេសសម្រាប់ដាក់ផ្កាក៏ដោយ របៀបធ្វើបែបនេះគឺមានប្រយោជន៍អាចប្រើជាសម្លៀកបំពាក់ថូផ្កាបានយ៉ាងរីករាយ ដោយគ្រាន់តែដាក់វាគ្របលើដបទទេជាការស្រេច។

កាកិជិគឹ នៅប្រទេសជប៉ុនបានរំលេចនូវអក្សរផ្ចង់ ឬ គំនូរ ដែលមានស៊ុមក្រណាត់យ៉ាងស្រស់ស្អាត។ ក្រណាត់ត្បាញយ៉ាងល្អិតល្អន់បែបប្រពៃណីជប៉ុនត្រូវបានគេហៅថា ហ្យ៉ូសូហ្គិរិ (hyosogire)។ ក្រឡាខុសៗគ្នា ដូចជាស្ទីលគំនូរបែបធម្មជាតិ មានដូចជាពពក និងទឹក ឬ បែបរុក្ខជាតិ ដូចជាផ្កាអ៊ុម៉ិ(ume) និងដើមស្រល់(matsu)។ ក្រណាត់ល្អៗទាំងនេះត្បាញដោយខ្សែអំបោះមាសយ៉ាងស្រស់ស្អាត ឬ ពណ៌ប្រពៃណីផ្សេងៗ ដែលធ្វើឱ្យមានភាពទាក់ទាញពីក្នុងក្រឡាទាំងនោះ។

*រូបលេខ១៖ ចាក់ទឹកចូលក្នុងដបទទេ ឬ របស់សម្រាប់ដាក់ទឹកផ្សេងទៀត ហើយពាក់ "សម្លៀកបំពាក់ថូផ្កា" ពីលើវា។*

*រូបលេខ២៖ ដាក់ផ្កាចូល ហើយនេះគឺជាថូផ្ការបស់អ្នក!*

*រូបលេខ៣៖ ហ្យ៉ូសូហ្គិរិ ដែលមានគំនូរពពកត្រូវបានគេនិយាយថាជាប្រផ្នូលល្អនាំឲ្យមានការអបអរសាទរ។*

*សហការដោយ៖ ក្រុមហ៊ុនតូរី, ស្ទូឌីយោឌីហ្សាញអ៊ិហ្គារ៉ាស៊ិ (TORII Co., Ltd., Igarashi Design Studio)*

*ទស្សនាវដ្តី "និប៉ុនិកា" លេខ២៩*
*បោះពុម្ពផ្សាយដោយក្រសួងការបរទេសជប៉ុន*
*២-២-១ កាស៊ឹមិហ្គាសិគិ សង្កាត់ជិយ៉ូដា ទីក្រុងតូក្យូ ១០០-៨៩១៩ ប្រទេសជប៉ុន*
*គេហទំព័រផ្លូវការរបស់ក្រសួង https://www.mofa.go.jp/*
*គេហទំព័រដែលផ្តល់ព័ត៌មានអំពីជប៉ុន https://web-japan.org/*